ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Dec-2021, 14:27
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**

Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០៤/២៣-កញ្ញា-២០០៩-អ.វ.ត.ក/អ.ជ.ត.ក (០៦)

Case File/Dossier N°. 004/23-09-2021-ECCC/SC(06)

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម ម៉ុង មុនីចរិយា** |
| | **ចៅក្រម Maureen Harding CLARK** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខាន របស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវ ដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.

| | |
|---|---|
| **<u>សហព្រះរាជអាជ្ញា</u>** | **<u>ជនជាប់ចោទ</u>** |
| ជា លាង | យឹម ទិត្យ |
| Brenda J. HOLLIS | |
| | **<u>សហមេធាវីជនជាប់ចោទ</u>** |

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤</u>**

លោក សូ មូហ្សេន្ទី
Suzana TOMANOVIĆ

01684589

សំណុំរឿងលេខៈ ០០៤/២៣-កញ្ញា-២០០៩-អ.វ.ត.ក/អ.ជ.ត.ក (០៦)

ឯកសារលេខ 2/1/1/1

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” ឬ“អង្គជំនុំជម្រះ” និង “អ.វ.ត.ក.” នីមួយៗ) បានទទួល“បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.” (“សំណើ”)[1]។

## ក. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបានលើកឡើងថា សហព្រះរាជអាជ្ញាជាតិពុំយល់ស្របជាមួយនឹងការចោទប្រកាន់បទឧក្រិដ្ឋថ្មីដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[2]។ នៅថ្ងៃដដែលនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបីក្នុងសំណុំរឿង ០០៤ ស្នើសុំឱ្យបើកកិច្ចស៊ើបសួរលើការចោទប្រកាន់នៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦[3]។

3. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនដោយបានប្រកាសថា អង្គជំនុំជម្រះពុំអាចរកសម្លេងគាំទ្រពីចៅក្រមយ៉ាងតិចបួនរូបក្នុងការសម្រេចលើការខ្វែងយោបល់គ្នានៅចំពោះមុខខ្លួន និងថា កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គប្បីត្រូវបានយកទៅអនុវត្ត[4]។

---

[1] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ឯកសារលេខ 2 ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២១ (“សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ”)។

[2] កំណត់ហេតុលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីអង្គហេតុ និងសំអាងហេតុសម្រាប់ការខ្វែងយោបល់ ដោយអនុលោមតាមវិធាន ៧១(២) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ 1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ D1។

[4] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងទៅនឹងការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាដោយអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ ឯកសារលេខ D1/1.3។

4. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី និងបានបញ្ជូនសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេត[5]។ នៅចន្លោះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១១ និង ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបន្ទាប់មកបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនបួនដើម្បីពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ[6]។

5. ការខ្វែងយោបល់គ្នាជាសម្ងាត់របស់សហចៅក្រមស៊ើបអង្កេតក្នុងរឿងក្តីនេះ ត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧[7]។

6. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ ពីបទរំលោភបំពានលើមាត្រា ៥០១ និង ៥០៦ (អំពើមនុស្សឃាតគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[8]។ តាមរយៈដីកាចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិនិត្យឡើងវិញលើបទចោទប្រឆាំងនឹង យឹម ទិត្យ និងបានបន្ថែមទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធទៅនឹង

---

[5] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ ឯកសារលេខ D1/1។

[6] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ D65។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាលើផ្លូវភេទ ឬយេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ D191។ ការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមាក់ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ D254/1។ ការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងតំបន់ ១ និង ៤ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ D272/1។

[7] *សូមមើល* ដីកាដំណោះស្រាយ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ ឯកសារលេខ D382 ("ដីកាបញ្ជូនទៅជំនុំជម្រះ (ឯកសារលេខ D382)") កថាខណ្ឌ ៣, ៧, ២១។ ដីកាលើកលែងចោទប្រកាន់រឿងក្តីប្រឆាំងនឹង យឹម ទិត្យ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ D381("ដីកាបញ្ជូនទៅជំនុំជម្រះ(ឯកសារលេខ D381)") កថាខណ្ឌ ១៣។

[8] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ D281។

បទឧក្រិដ្ឋដែលបានចោទពីមុន[9]។

7. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ អនុលោមតាម វិធាន ៦៦(១) នៃវិធានផ្ទៃក្នុង[10]។ នៅថ្ងៃដដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយបានដកចេញនូវអង្គហេតុចោទប្រកាន់មួយចំនួនអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[11]។ នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតចេញសេចក្តីជូនដំណឹងលើកទីពីរស្តីពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ[12]។

8. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីនៃសំណុំរឿង ០០៤/២ ថា ខ្លួនបានពិចារណាចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដែលត្រូវបានអនុញ្ញាតដោយច្បាប់ជាធរមាន[13]។ សេចក្តីសម្រេចនេះបានជូនដំណឹងដល់ភាគីនៃសំណុំរឿង ០០៤។[14]

9. នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅសហព្រះរាជ

---

[9] ដីកាសម្រេចកែប្រែបទចោទប្រឆាំងនឹង យឹម ទិត្យ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារលេខ D350។ ការជូនដំណឹងអំពីដីកាសម្រេចកែប្រែបទចោទប្រឆាំងនឹង យឹម ទិត្យ ឧបសម្ព័ន្ធ ១ ភ្ជាប់ទៅនឹងដីកាសម្រេចកែប្រែបទចោទ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារលេខ D350.1។

[10] សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង យឹម ទិត្យ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារលេខ D358។

[11] ដីកាសម្រេចកាត់បន្ថែមវិសាលភាពនៃកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារលេខ D359។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងទៅនឹងការចោទប្រកាន់នីមួយៗ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ D302/3។ សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមនៃការទទួលខុសត្រូវតាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ D342។ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧ ឯកសារលេខ D349។ សេចក្តីជូនដំណឹងយោងតាមវិធាន *៦៦ស្ទួន*(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារលេខ D354។

[12] សេចក្តីជូនដំណឹងលើកទីពីរអំពីការបិទកិច្ចស៊ើបសួរ យឹម ទិត្យ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D368។

[13] ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D355/1 កថាខណ្ឌ ១៣ ដល់ ១៦។

[14] *សូមមើល* ដីកាបញ្ជូនទៅជំនុំជម្រះ (D382) កថាខណ្ឌ ១៣។

អាជ្ញា អញ្ជើញឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរផ្អែកតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង[15]។ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរ និងបានស្នើថា រាល់បទចោទទាំងអស់លើ យឹម ទិត្យ ត្រូវលើកលែងចោទប្រកាន់ ដោយសារគាត់ពុំស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[16]។ នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរស្នើសុំឱ្យធ្វើការចោទប្រកាន់ និងបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ[17]។

10. សហចៅក្រមស៊ើបអង្កេត បានចុះកំណត់ត្រាការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយផ្សេងគ្នា និងផ្ទុយគ្នានៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៩[18]។ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ដោយបានលើកលែងចោទប្រកាន់ទាំងអស់លើ យឹម ទិត្យ[19] ខណៈពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង យឹម ទិត្យ[20]។

11. បន្ទាប់ពីបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ បានដាក់នៅមុខអង្គបុរេជំនុំជម្រះ ព្រមទាំងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ និងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះបានចេញ*សេចក្តីពិចារណា*របស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នីមួយៗនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ដោយបានបញ្ជាក់ថា ខ្លួនខ្វះមតិភាគច្រើនលើសលុបដែលតម្រូវសម្រាប់ការសម្រេចលើអង្គសេចក្តី

---

[15] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨ ឯកសារលេខ D378។

[16] ដីកាសន្និដ្ឋានស្ថាពរពាក់ព័ន្ធនឹង យឹម ទិត្យ យោងតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារលេខ D378/1។

[17] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារលេខ D378/2។

[18] *សូមមើល* ដីកាបញ្ជូនទៅជំនុំជម្រះ (D382) កថាខណ្ឌ ២១។ ដីកាលើកលែងចោទប្រកាន់ (D381) កថាខណ្ឌ ១៣។

[19] ដីកាលើកលែងចោទប្រកាន់ (D381)។

[20] ដីកាបញ្ជូនទៅជំនុំជម្រះ (D382) (បន្ថែមទៅនឹងដីកាបញ្ជូនទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ចប់ជាផ្លូវការនូវកិច្ចស៊ើបសួរលើអង្គហេតុដែលត្រូវបានដកចេញ នៅក្នុងដីកាសម្រេចយោងតាមវិធាន ៦៦ *ស្ទួន*នៃវិធានផ្ទៃក្នុង និងបានចេញដីកាលើកលែងចោទប្រកាន់ផ្នែកខ្លះ ដែលបានលើកលែងចោទប្រកាន់បទចោទមួយចំនួនប្រឆាំងនឹង យឹម ទិត្យ)។

នៃបណ្ដឹងឧទ្ធរណ៍ទាំងនេះប្រឆាំងនឹងដីកាដំណោះស្រាយនោះ[21]។ *សេចក្ដីពិចារណា* ត្រូវបានជូនដំណឹងជាផ្លូវការនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២១ និងនៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំពន្យារពេលដាក់សារណាចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[22]។ នៅថ្ងៃដដែល យឹម ទិត្យ បានឆ្លើយតបទៅនឹងសំណើនោះ ដោយជំទាស់ទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា *សេចក្ដីពិចារណា* អាចធ្វើបណ្ដឹងសាទុក្ខនៅមុខអង្គជំនុំជម្រះតុលាការកំពូលបាន[23]។ នៅថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០២១ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្ដីសម្រេចរបស់ខ្លួនលើសំណើ និងបានបញ្ជាក់ថា ខ្លួនពុំអាចពិនិត្យលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ រហូតទាល់តែសំណើនោះត្រូវបានបំភ្លឺពេញលេញ និងបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអន្តរជាតិដាក់សារណានោះ[24]។

12. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១ យឹម ទិត្យ បានដាក់សំណើនៅមុខសហចៅក្រមស៊ើបអង្កេតសុំបញ្ចប់ភ្លាមៗ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនូវសំណុំរឿង ០០៤[25]។ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ តាមរយៈអ៊ីម៉ែលថា ខ្លួននឹងពុំសម្រេចលើបញ្ហាថាតើ ត្រូវបញ្ចប់ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនូវរឿងក្ដីនេះ រហូតទាល់តែអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចរបស់ខ្លួនក្នុងកិច្ចដំណើរការនីតិវិធីនេះជាមុនសិន[26]។

---

[21] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D381/45 និង D382/43 កថាខណ្ឌ ១១៦។

[22] អ៊ីម៉ែលពីសហព្រះរាជអាជ្ញាអន្តរជាតិ‘សំណើរបស់ហព្រះរាជអាជ្ញាអន្តរជាតិសុំបន្ថែមពេលវេលាដាក់សារណាក្នុងសំណុំរឿង ០០៤’ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២១។

[23] អ៊ីម៉ែលពីមេធាវីការពារក្ដី ‘RE: សំណើរបស់ហព្រះរាជអាជ្ញាអន្តរជាតិសុំបន្ថែមពេលវេលាដាក់សារណាក្នុងសំណុំរឿង ០០៤’ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២១។

[24] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបន្ថែមពេលវេលាដាក់សារណាពាក់ព័ន្ធទៅនឹងសេចក្ដីពិចារណាលើដីកាដំណោះស្រាយរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ 2/2។

[25] សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតបញ្ចប់ភ្លាមៗ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនៃសំណុំរឿង ០០៤ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១ ឯកសារលេខ D386។

[26] អ៊ីម៉ែលពីសហចៅក្រមស៊ើបអង្កេត‘សេចក្ដីជូនដំណឹងដល់ភាគីក្នុងសំណុំរឿង ០០៣ និង ០០៤’ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១។

## ខ. សារណា

13. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា បណ្តឹងសាទុក្ខត្រូវបានអនុញ្ញាតតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក. មាត្រា ៣៣ ថ្មី និង ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីប្រើប្រាស់យុត្តាធិការដែលជាឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការការពារអត្ថប្រយោជន៍យុត្តិធម៌ និងរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[27] និងបានអះអាងថា ការខកខានរបស់អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងសហចៅក្រមស៊ើបអង្កេតក្នុងការប្រើប្រាស់យុត្តាធិការរបស់ខ្លួនលើរឿងក្តី បានធ្វើឱ្យភាពទាល់ច្រកផ្នែកនីតិវិធីនេះចេះតែបន្ត និងមានហានិភ័យនៃព្យសនកម្មដែលពុំអាចស្រោចស្រង់បានដល់ការគ្រប់គ្រងយុត្តិធម៌ក្នុងសំណុំរឿង ០០៤[28]។ បើគ្មានកិច្ចអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូលទេ កិច្ចដំណើរការនីតិវិធីនៃរឿងក្តីនេះនៅតែពុំមានច្រកចេញរួចដែលនេះ គឺជាយុត្តិនិសេធក្នុងការរំលោភបំពានលើអាណត្តិរបស់ អ.វ.ត.ក. និងគោលការណ៍ជាសារវ័ន្ត[29]
។

14. យោងតាមមេធាវីការពារក្តី យឹម ទិត្យ បានឱ្យដឹងថា បណ្តឹងសាទុក្ខនេះពុំអាចទទួលយកបានទេ ដោយសារសហចៅក្រមស៊ើបអង្កេតមានយុត្តាធិការពិសេសលើសំណុំរឿង ០០៤ និងថា ជាការលើកបញ្ហាដដែលឡើងវិញពីសំណុំរឿង ០០៤/២ ហើយពុំមានហេតុផលសមស្រប ឬការប្រែប្រួលនៃកាលៈទេសៈដែលតម្រូវឱ្យអង្គជំនុំជម្រះពុំត្រូវអនុវត្តតាមការយល់ឃើញរបស់ខ្លួនពីមុននោះឡើយ[30]។

---

[27] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣១ ដល់ ៣៥។

[28] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣២ ដល់ ៣៤។

[29] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥១។

[30] សារណាតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចបានតម្រូវឱ្យក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២១ ឯកសារលេខ 2/1 ("សារណាតបរបស់ យឹម ទិត្យ") កថាខណ្ឌ ២០ ដល់ ៣១។

15. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា សហចៅក្រមស៊ើបអង្កេតពុំមានយុត្តាធិការពិសេសលើសំណុំរឿងនេះទេ និងថា មានហេតុផលសមស្របដែលអង្គជំនុំជម្រះតុលាការកំពូលពុំត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់ខ្លួនក្នុងសំណុំរឿង ០០៤/២[31]។

16. ជាសរុប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីបង្គាប់ឱ្យសំណុំរឿងនេះបន្តដំណើរការទៅជំនុំជម្រះ ដោយសារ (១) ដីកាដំណោះស្រាយដែលផ្ទុយគ្នា ពុំត្រូវបានចេញដោយខុសច្បាប់ឡើយ (២) ដីកាដំណោះស្រាយផ្ទុយគ្នានេះមានសុពលភាព បើទោះបីជាការចេញដីកាពីរក្នុងពេលតែមួយនោះខុសច្បាប់ក៏ដោយ (៣) ដីកាបញ្ជូនទៅជំនុំជម្រះពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប និង (៤) សំណុំរឿង ០០៤ ពុំខុសច្បាប់ឡើយ[32]។

## គ. ច្បាប់ជាធរមាន

17. យោងតាមមាត្រា ៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា អង្គជំនុំជម្រះតុលាការកំពូលគឺកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសម្រេចសេចក្តីចុងក្រោយផង។

18. ដោយស្របតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ដូចបានកំណត់ក្នុងវិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖ ក) កំហុសលើអង្គច្បាប់ ដែលនាំអោយមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ ខ) កំហុសនៃអង្គហេតុដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

---

[31] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសារណាតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងសាទុក្ខស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវឱ្យក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០២១ ឯកសារលេខ 2/1/1 ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ") កថាខណ្ឌ ១ ដល់ ១១។

[32] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៦ ដល់ ៧១។

## ឃ.ការពិភាក្សា

*ភាពអាចទទួលយកបានតាមទម្រង់នៃបណ្តឹងសាទុក្ខតាមវិធាន ១០៤ និង ១០៥*

19. ក្នុងការគាំទ្រសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងទៅលើមាត្រា ១២(២) នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក. មាត្រា ៣៣ ថ្មី និង ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ដែលពុំជាប់ពាក់ព័ន្ធទៅនឹងការដាក់បណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះនេះ។ អង្គជំនុំជម្រះបានកំណត់ពីមុនរួចហើយថា "យន្តការផ្ទែកនីតិវិធីផ្សេងគ្នាដែលបានបង្កើតឡើងក្នុងវិធានផ្ទៃក្នុង បានណែនាំភាគីអំពីវិធីសាស្ត្រក្នុងការដាក់បណ្តឹងសាទុក្ខចំពោះមុខអង្គជំនុំជម្រះនេះ [..]។ វិធានផ្ទៃក្នុងបានកម្រិតសមត្ថកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ឬសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកតាមវិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុង"[33]។

20. សំណើបច្ចុប្បន្នពុំមែនជាបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឬសាលក្រមដោយអនុលោមតាមវិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុងនោះទេ ប៉ុន្តែគឺបណ្តឹងសាទុក្ខប្រឆាំងនឹង"ការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវឱ្យក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក."[34]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពុំអាចទទួលយកបានតាមទម្រង់។ ដូចនេះ អង្គជំនុំជម្រះនឹងហៅបណ្តឹងសាទុក្ខនេះថាជាសំណើសម្រាប់គោលបំណងនៃការពិភាក្សានេះ។

*ភាពទទួលយកបានតាមទម្រង់ដោយសារអត្ថប្រយោជន៍យុត្តិធម៌*

21. ដោយហេតុថា អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិពុំមែនជាបណ្តឹងសាទុក្ខស្របតាមវិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យប្រើប្រាស់យុត្តាធិការដែលជាឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីការពារអត្ថប្រយោជន៍យុត្តិធម៌ និងរក្សាសុចរិតភាព

---

[33] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១ ឯកសារលេខ 3/1/1/1, ("សេចក្តីសម្រេចសំណុំរឿង ០០៣") កថាខណ្ឌ ២៧។

[34] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារលេខ 2។

នៃកិច្ចដំណើរការនីតិវិធី[35]។ ប្រសិនបើគ្មានការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលទេ កិច្ចដំណើរការនីតិវិធីនៃរឿងក្ដីនេះនៅតែពុំមានច្រកចេញរួច ដែលនេះ គឺជាយុត្តិនិសេធក្នុងការរំលោភបំពានលើអាណត្តិរបស់ អ.វ.ត.ក. និងគោលការណ៍ជាសារវ័ន្ត[36]។

22. អង្គជំនុំជម្រះរំឭកថា ម្ដងម្កាល អង្គជំនុំជម្រះទទួលយកសំណើរបស់ភាគីសុំការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់[37]។ សំណើសុំការបំភ្លឺ ឬសេចក្ដីណែនាំផ្នែកច្បាប់ អាចចេញពីស្ថាប័នតុលាការដទៃទៀត ឬភាគីក្នុងកិច្ចដំណើរការនីតិវិធី[38]។

23. ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិថា មធ្យោបាយតែមួយគត់សម្រាប់ដោះស្រាយភាពមិនប្រាកដប្រជាក្នុងរឿងក្ដីនេះ និងរារាំង"សក្ដានុភាពនៃការជំទាស់តវ៉ាគ្មានទីបញ្ចប់" គឺតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលចាត់វិធានការ[39]។ ក្នុងសេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ អង្គជំនុំជម្រះបានរំឭកពីច្បាប់រ៉ូម៉ាំងម៉ាកស៊ីម (maxim "*ubi jus, ibi remedium*) ថា ទីណាមានសិទ្ធិទីនោះមានសំណង ទីណាច្បាប់បង្កើតសិទ្ធិ ទីនោះគប្បីមានសំណងតបទៅនឹងការរំលោភសិទ្ធិ"[40] និងថា "កាលៈទេសៈពិសេសនៃរឿងក្ដី ០០៤/២ តម្រូវថា សហព្រះរាជអាជ្ញាអន្តរជាតិ អោ អាន ដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជន មានសិទ្ធិទទួលបានការរំពឹងទុក និងទទួលបានការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់

---

[35] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣១ ដល់ ៣៥។

[36] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៤។

[37] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារលេខ E284/2/1/2 សេចក្ដីសម្រេចសំណុំរឿង ០០៤/២ (E004/2/1/1/2)។ សេចក្ដីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំចំណាត់ការចាំបាច់ពីអង្គជំនុំជម្រះតុលាការកំពូលក្នុងការធានានូវសិទ្ធិជាសារវ័ន្តរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានការតំណាងនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២០ ឯកសារលេខ E004/2/6។

[38] សេចក្ដីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្ដី អៀង ធីរិទ្ធ សុំការណែនាំ និងការបញ្ជាក់បំភ្លឺ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E138/1/10/1/5/8/2 កថាខណ្ឌ ១២។

[39] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១៥។

[40] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូងនូវអានុភាពនៃសំណុំរឿង ០០៤/២ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1/1/2 ("សេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2)") កថាខណ្ឌ ៥៩។

[...]។ ការទុកឱ្យស្ថិតក្នុងភាពមិនច្បាស់លាស់តាមផ្លូវតុលាការ បានបំពានជាសារវន្តនូវក្តីរំពឹងត្រឹមត្រូវសមស្របនោះ។ ដូច្នេះ អង្គជំនុំជម្រះនេះ គឺជាតុលាការចុងក្រោយក្នុងការផ្តល់នូវការបំភ្លឺនេះ”[41]។

24. អាស្រ័យហេតុនេះ ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះនឹងត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន និងផ្តល់ការបំភ្លឺ និងសច្ចភាពផ្នែកច្បាប់លើបញ្ហាតែមួយប៉ុណ្ណោះ គឺស្ថានភាពនៃសំណុំរឿង ០០៤ ស្របតាមយុត្តិសាស្ត្ររបស់ខ្លួនក្នុងសំណុំរឿង ០០៤/២ និង ០០៣ និងក្នុងនាមជាតុលាការចុងក្រោយ[42]។

*កំណត់សម្គាល់បឋម*

25. អង្គជំនុំជម្រះរំឭកថា សេចក្តីពិចារណាប្រហាក់ប្រហែលគ្នាត្រូវបានចេញដោយអង្គបុរេជំនុំជម្រះនៅក្នុងរឿងក្តីជាច្រើន មានដូចជា រឿងក្តី ០០៤/២ ០០៣ និង ០០៤។ ដោយសារការទាល់ច្រកដូចគ្នាដែលកើតមានលើរឿងក្តីទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំច្រំដែលនូវការបំភ្លឺ និងសច្ចភាពផ្នែកច្បាប់ក្រោយពីការចេញសេចក្តីពិចារណានានានោះ និងលើកទឡ្ហីករណ៍ប្រហាក់ប្រហែលគ្នាក្នុងការគាំទ្រ។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីបង្គាប់ឱ្យសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដោយសារ (១) ដីកាដំណោះស្រាយផ្ទុយគ្នាពុំត្រូវបានចេញដោយខុសច្បាប់ (២) ដីកាដំណោះស្រាយផ្ទុយគ្នាមានសុពលភាព បើទោះបីការចេញពីរដំណាលគ្នាគឺជាការខុសច្បាប់ក៏ដោយ (៣) ដីកាបញ្ជូនទៅជំនុំជម្រះពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប[43]។

26. អង្គជំនុំជម្រះបញ្ជាក់ថា ការបំភ្លឺ និងសច្ចភាពផ្លូវច្បាប់ ត្រូវបានបង្ហាញច្បាស់លាស់ក្នុងសេចក្តីសម្រេចរបស់ខ្លួននៃសំណុំរឿង ០០៤/២ និង ០០៣ ពាក់ព័ន្ធទៅនឹងធម្មានុរូបនៃដីកាដំណោះស្រាយផ្ទុយគ្នា បញ្ហាថាតើដីកានោះមានសុពលភាព ដែរ ឬយ៉ាងណា និងបញ្ហាដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប។ អង្គជំនុំជម្រះនឹងពុំធ្វើការជំនុំជម្រះលើបញ្ហានេះម្តងទៀតទេ ក្រៅតែពីការពង្រឹងការយល់ឃើញរបស់ខ្លួនបន្ថែម។

---

[41] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៦០។

[42] មាត្រា ៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[43] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៦ ដល់ ៧១។

27. ក្នុងសេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា "ទោះបីជាមានសេចក្ដីប្រកាស*ឯកច្ឆន្ទ*ថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញជាដីកាដំណោះស្រាយពីរដាច់ដោយឡែក ហើយផ្ទុយគ្នា ត្រូវចាត់ទុកជាមោឃៈក៏ដោយ ក៏ចៅក្រមអង្គបុរេជំនុំជម្រះផ្ដល់សេចក្ដីពិចារណារបស់ខ្លួនលើសុពលភាពនៃដីកាដំណោះស្រាយផ្ទុយគ្នានេះដែរ។ នេះបង្ហាញជាក់ច្បាស់ថា ការធ្វើបែបនេះ គឺជាការអនុវត្តន៍ដែលពុំចាំបាច់។ រីតតែមិនជាប់ពាក់ព័ន្ធទៅទៀតដែលថា អង្គបុរេជំនុំជម្រះពុំបានទទួលមតិភាគច្រើនលើសលុប ដែលតម្រូវក្នុងការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ភាគីប្រឆាំងនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា ដោយសារសេចក្ដីពិចារណាក្នុងផ្នែកនេះក្លាយទៅជារឿងឥតចាំបាច់"[44]។ អង្គជំនុំជម្រះបានកំណត់ថា អង្គបុរេជំនុំជម្រះបន្ទាប់ពីបានបញ្ជាក់អះអាងពីសិទ្ធិអំណាចនៃកិច្ចស៊ើបសួររបស់ខ្លួន"គប្បីបានធ្វើលើសពីការប្រកាសភាពខុសច្បាប់នៃស្ថានការណ៍ដែលពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងអាចចេញដីកាដំណោះស្រាយសុពលភាពរបស់ខ្លួនថ្មីបាន។ ទោះជាយ៉ាងណាក្ដី អង្គបុរេជំនុំជម្រះពុំបានជ្រើសយកវិធីសាស្ត្របែបនេះទេ [...] គប្បីបានដើរមួយជំហានបន្ថែមទៀត និងបានផ្ដល់នូវការសម្រេចស្ថាពរជាក់ស្ដែងមួយ"[45]។ ក្រោយពីបានវាយតម្លៃលើផលប៉ះពាល់នៃការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា អង្គជំនុំជម្រះបានដោះស្រាយលើបញ្ហានៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ក្នុងការបញ្ជូនទៅជំនុំជម្រះដោយគ្មានទាំងដីកាដំណោះស្រាយសុពលភាព និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ "ចម្លើយដែលច្បាស់លាស់នោះគឺថា ទេ"[46]។

28. ទាក់ទងទៅនឹងរឿងក្ដី ០០៣ អង្គជំនុំជម្រះបានដឹងអំពីការចេញសេចក្ដីពិចារណាជាសាធារណៈ និងប្រកាសថា ជាការពេញលេញ[47]។ អង្គជំនុំជម្រះបានកំណត់ថា "ផលវិបាកជាក់លាក់ច្បាស់លាស់នៃការប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះដែលថា សេចក្ដីពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៣ បិទផ្លូវតវ៉ាដោយផ្អែកតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង បានបង្ហាញថា ជាការបញ្ចប់រឿងក្ដីនេះ។ ការប្រកាសជាឯកច្ឆន្ទដោយចៅក្រមប្រាំរូបនៃអង្គបុរេជំនុំជម្រះ បានពង្រឹងការសម្រេចរបស់ខ្លួនដែលធ្វើឱ្យបណ្ដឹង

[44] សេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៥៣។

[45] សេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៦១។

[46] សេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៦៨។

[47] សេចក្ដីសម្រេចនៃសំណុំរឿង ០០៣ កថាខណ្ឌ ៣៤។

ឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ពុំទទួលបានជោគជ័យ ដូច្នេះបិទបណ្ដឹងឧទ្ធរណ៍ និងបញ្ចប់រឿងក្ដី"[48]។

29. ដូចគ្នាដែរ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងរឿងក្ដី ០០៤ ត្រូវបានធ្វើឡើងជាសាធារណៈនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១[49]។ អង្គបុរេជំនុំជម្រះជាឯកច្ឆន្ទ"បានប្រកាសថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ រំលោភលើក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក. [...]" និងថា "ស្របតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចបច្ចុប្បន្នបិទផ្លូវតវ៉ា"[50]។ បន្ទាប់មក ចៅក្រមអង្គបុរេជំនុំជម្រះបានចុះហត្ថលេខាលើសេចក្ដីសម្រេចនេះ។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤ ជាការបញ្ចប់រឿងក្ដីនេះ។ អំណះអំណាងប្រហាក់ប្រហែលគ្នានេះដែលបានលើកឡើងដើម្បីគាំទ្រក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ត្រូវបដិសេធចោល ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិខកខានក្នុងការបង្ហាញនូវហេតុផលដែលអាចឱ្យអង្គជំនុំជម្រះជឿបានដើម្បីកែប្រែការសម្រេចរបស់ខ្លួនកន្លងមក ក្នុងសំណុំរឿង ០០៤/២ និង ០០៣ ដែលស្ថិតក្រោមកាលៈទេសៈដូចគ្នា។

*ស្ថានភាពនៃសំណុំរឿង ០០៤*

30. អង្គជំនុំជម្រះបានបញ្ជាក់ពីដំបូងរួចហើយថា "នេះគឺជាគោលការណ៍ទូទៅនៃនីតិរដ្ឋដែលជាការពុំសមស្របក្នុងការទុកអត្ថិភាពបញ្ហាផ្នែកច្បាប់ចោលពុំដោះស្រាយនោះទេ"[51]។ អង្គជំនុំជម្រះកំណត់ថា នេះជាការទទួលខុសត្រូវរបស់តុលាការ និងជាពិសេស ចៅក្រមត្រូវជំនុំជម្រះបញ្ហានៅចំពោះមុខខ្លួនរហូតទាល់តែត្រូវបញ្ចប់។ ការធ្វើសេចក្ដីសម្រេច មានទំនាក់ទំនងស្អិតរមួតជាមួយនឹងការផ្ដល់យុត្តិធម៌ក្នុងតុលាការ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នេះពុំមែនជាការពិភាក្សាលើបញ្ហាថាតើ សេចក្ដីសម្រេចនោះល្អ ឬមិនល្អនោះទេ ប៉ុន្តែជាសេចក្ដីសម្រេចមួយដែលអាចអនុវត្តបាន និងស្ថាពរ ដោយសារលក្ខខណ្ឌតម្រូវនៃ

[48] សេចក្ដីសម្រេចនៃសំណុំរឿង ០០៣ កថាខណ្ឌ ៣៥។

[49] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D381/45 និង D382/43។

[50] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ ឯកសារលេខ D381/45 និង D382/43 ផ្នែកសម្រេចសេចក្ដី។

[51] សេចក្ដីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៦៥។

វិសាលភាពយុត្តិធម៌។ ផ្អែកតាមទស្សនៈរបស់អង្គជំនុំជម្រះឃើញថា ការរងទុក្ខតាមផ្លូវតុលាការពុំមែនជាជម្រើសក្នុងប្រព័ន្ធច្បាប់ឡើយ ដែលនេះជាការពុំសមស្របសម្រាប់អ្នកអនុវត្តច្បាប់ និងធ្វើឱ្យមានការបាត់បង់ក្តីសង្ឃឹមសម្រាប់ភាគី ជនសង្ស័យ និងជនរងគ្រោះ។ យុត្តិធម៌ត្រូវតែផ្តល់ឱ្យបានឆាប់រហ័ស និងចប់ចុងចប់ដើម។

31. ដូច្នេះ ក្នុងការសម្រេចពីស្ថានភាពសំណុំរឿង ០០៤ អង្គជំនុំជម្រះសង្កេតឃើញថា រឿងក្តីនេះពុំបានអាចបន្តនៅពុំរ៉ៃតទៅទៀត។ ជាការកត់សម្គាល់ បើទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឡើងថា សំណុំរឿង ០០៤ គប្បីត្រូវបញ្ជូនទៅជំនុំជម្រះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះពុំបានចេញដីកាបញ្ជូនទៅជំនុំជម្រះស្របតាមវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះរំឭកថា សំណុំរឿង ០០៤/២ និង ០០៣ ត្រូវបានបញ្ចប់ដោយសារ "ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះជាក់លាក់ និងអាចអនុវត្តបាន"[52]។ ក្នុងសំណុំរឿង ០០៤ អត្ថិភាពនៃបញ្ហាដូចគ្នា គឺពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះជាក់លាក់ និងអាចអនុវត្តបានដែលធ្វើឱ្យរឿងក្តីនេះវិវឌ្ឍន៍ទៅមុខបាន។ ជាលទ្ធផល សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបន្តនីតិវិធីទៅជំនុំជម្រះនៃសំណុំរឿង ០០៤ ត្រូវបដិសេធចោល។

---

[52] សេចក្តីសម្រេចនៃសំណុំរឿង ០០៤/២ (E004/2/1/1/2) កថាខណ្ឌ ៦៩ ដល់ ៧១ សេចក្តីសម្រេចនៃសំណុំរឿង ០០៣ កថាខណ្ឌ ៤៤។

## ខ. <u>ផ្នែកសម្រេចសេចក្ដី</u>

32. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ

**ប្រកាស**ថា ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះជាក់លាក់ និងអាចអនុវត្តបាន សំណុំរឿង ០០៤ ត្រូវបញ្ចប់

**បដិសេធ**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

ចៅក្រម Maureen HARDING CLARK មានមតិជំទាស់។

ភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

ចៅក្រម **គង់ ស្រីម** ប្រធាន

Judge Chandra Nihal JAYASINGHE

ចៅក្រម **សោម សិរីវឌ្ឍ**

Judge Florence Ndepele MWACHANDE-MUMBA

ចៅក្រម **ម៉ុង មុនីចរិយា**

ចៅក្រម **យ៉ា ណារិន**

## I. ប្រវត្តិនីតិវិធី

1. រឿងក្ដីនេះប្រហាក់ប្រហែលគ្នាទៅនឹងរឿងក្ដី ០០៣ ប្រឆាំងនឹង មាស មុត[53] និងរឿងក្ដីពីដំបូង ០០៤/២ ប្រឆាំងនឹង អោ អាន[54]។ ដូចក្នុងរឿងក្ដី ០០៣ ដែរ សំណើនេះពាក់ព័ន្ធទៅនឹងផលវិបាកនៃសេចក្ដីសម្រេចដែលខុសប្លែកធម្មតារបស់អង្គបុរេជំនុំជម្រះ ដែលចៅក្រមនៃអង្គជំនុំជម្រះនេះបានខ្វែងយោបល់គ្នាលើសុពលភាពនៃដីកាដំណោះស្រាយពីរផ្ទុយគ្នាដែលចេញដោយសហចៅក្រមស៊ើបអង្កេត។ រឿងក្ដីទាំងបីនេះមានប្រវត្តិដូចគ្នា កកើតចេញពីវិធីសាស្ត្រផ្ទុយគ្នាក្នុងការបំពេញកិច្ចស៊ើបសួរបន្ថែមរវាងសហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិ។ សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីប្រឆាំងនឹងក្រុមទីពីរនៃមេដឹកនាំលំដាប់ទីពីរតាមភូមិភាគរបស់បក្សកុម្មុយនីស្តកម្ពុជា(“កម្ពុជាប្រជាធិបតេយ្យ”) ខណៈពេលដែលកិច្ចស៊ើបសួរបន្ថែមនេះត្រូវបានជំទាស់ និងនៅតែជំទាស់យ៉ាងខ្លាំងក្លាដោយសហព្រះរាជអាជ្ញាជាតិផ្អែកលើមូលដ្ឋាននៃគោលនយោបាយ។

2. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកការខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះដោយអនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង[55]។ នៅថ្ងៃដដែល សហព្រះរាជអាជ្ញាអន្តរជាតិបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ស្នើសុំឱ្យបើកកិច្ចស៊ើបសួរ

[53] *សូមមើល* សំណុំរឿង ០០៣/០៨-តុលា-២០២១-អ.វ.ត.ក/អ.ជ.ត.ក(០៥) សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១ ឯកសារលេខ 3/1/1/1 (“សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្ដី ០០៣ (3/1/1/1)”)។

[54] *សូមមើល* សំណុំរឿង ០០៤/២/០៧-កញ្ញា-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E004/2/1/1/2 ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០ (“សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្ដី ០០៤/២ (E004/2/1/1/2))”។

[55] ការខ្វែងយោបល់ ០០១/១៨-វិច្ឆិកា-២០០៨-អ.វ.ត.ក/អ.ប.ជ អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នាដោយអនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ 1 (ត្រូវបានបញ្ជូនដោយការិយាល័យរដ្ឋបាលទៅអង្គបុរេជំនុំជម្រះ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ)។

លើ យឹម ទិត្យ ដែលជាផ្នែកនៃសំណុំរឿង ០០៤ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[56]។

3. សេចក្តីលម្អិតនៃការខ្វែងយោបល់គ្នានោះត្រូវបានពិពណ៌នាពេញលេញនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងរឿងក្តី ០០៣ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២១[57]។ ជាសង្ខេប នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះដែលពុំអាចរកសម្លេងមតិភាគច្រើនលើសលុបពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា បានបង្គាប់សហព្រះរាជអាជ្ញាអន្តរជាតិឱ្យបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីទៅសហចៅក្រមស៊ើបអង្កេតដោយអនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង[58]។ ដូចបានរៀបរាប់នៅក្នុងមតិជំទាស់របស់ខ្ញុំក្នុងរឿងក្តី ០០៣ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបង្កើតជាគន្លងលំនាំឱ្យមានការខ្វែងយោបល់គ្នាចេះតែបន្តរវាងសហចៅក្រមជាតិ និងអន្តរជាតិនៃការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងរហូតមកទល់សព្វថ្ងៃនេះ។ រឿងក្តី ០០៤ និងអ្នករួមដំណើរជាមួយនោះរឿងក្តី ០០៣ និង ០០៤/២ បានវិវឌ្ឍន៍ទៅមុខតាមរយៈយន្តការស្វ័យប្រវត្តិរហូតដល់ដំណាក់កាលទាល់ច្រកនៅមុខអង្គបុរេជំនុំជម្រះ មុនមកដល់មុខអង្គជំនុំជម្រះតុលាការកំពូល។ ប្រតិបត្តិការបន្តនៃយន្តការស្វ័យប្រវត្តិដែលអនុញ្ញាតឱ្យរឿងក្តីនេះបន្តដំណើរទៅជំនុំជម្រះបាន ត្រូវបានធ្វើឱ្យមានការច្របូកច្របល់ដោយសារសេចក្តីសម្រេចនោះ។ នេះគឺជាឱកាសលើកទីបីដែលមតិយោបល់ពុំអាចអនុវត្តបានសមស្របរបស់អង្គបុរេជំនុំជម្រះ បានបង្ខំឱ្យសហព្រះរាជអាជ្ញាអន្តរជាតិស្វែងរកការអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល ដើម្បីជួយសង្គ្រោះរឿងក្តីនេះ ដែលកំពុងស្ថិតនៅក្នុងស្ថានភាពពុំច្បាស់លាស់ផ្នែកច្បាប់។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំកិច្ចអន្តរាគមន៍ក្នុងការបញ្ជូនរឿងក្តី ០០៤ ទៅជំនុំជម្រះស្របតាមយន្តការស្វ័យប្រវត្តិ និងគ្រប់កាលៈទេសៈត្រូវផ្តល់សច្ចភាពផ្នែកច្បាប់។

---

[56] សំណុំរឿង ០០៤/២០-វិច្ឆិកា-២០០៨/អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ D1 (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី (D1)”)។

[57] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី ០០៣ (3/1/1/1) កថាខណ្ឌ ១០-២៣។

[58] ការខ្វែងយោបល់គ្នា ០០១/១៨-វិច្ឆិកា-២០០៨-អ.វ.ត.ក./ក.ស.ច.ស សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ D1/1.3 (“សេចក្តីពិចារណាពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា (D1/1.3)”) កថាខណ្ឌ ៤៥។

4. ពាក់ព័ន្ធទៅនឹងប្រវត្តិនីតិវិធីនៃបរិបទ៖ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ស្នើសុំសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើ យឹម ទិត្យ ដែលជាផ្នែកនៃរឿងក្តី ០០៤[59]។

5. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីនោះពិពណ៌នាថា សហព្រះរាជអាជ្ញាអន្តរជាតិមានហេតុផលជឿជាក់ថា យឹម ទិត្យ (ហៅ តា ទិត្យ) *"ក្នុងមុខនាទីជាលេខាស្តីទីភូមិភាគពាយ័ព្យ និងលេខាតំបន់ ១ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងភូមិភាគនិរតី ដូចបានពិពណ៌នាក្នុងកថាខណ្ឌ ៨០ និង ៨១"*។ ឧក្រិដ្ឋកម្មទាំងនោះរួមមាន *"ការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យទាំងស្រុង ក្នុងអំឡុងពេលពាក់កណ្តាលឆ្នាំ ១៩៧៧ និងពាក់កណ្តាលឆ្នាំ ១៩៧៨ ដោយកម្មាភិបាលពីភូមិភាគនិរតី ដែលដឹកនាំដោយ តា ទិត្យ និង អ៊ឹម ចែម"*។ តាមការប៉ាន់ស្មានមានមនុស្សប្រមាណជា ៤០០.០០០ នាក់ស្លាប់ ក្នុងភូមិភាគកណ្តាល និង ៣៦០.០០០ នាក់ស្លាប់ ក្នុងភូមិភាគពាយ័ព្យ។

6. សហព្រះរាជអាជ្ញាអន្តរជាតិបន្ទាប់មកបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនបួន ដើម្បីពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង និងបានបន្ថែមទីតាំងឧក្រិដ្ឋកម្មថ្មីក្នុងតំបន់ ១ នៃភូមិភាគពាយ័ព្យ និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើខ្មែរក្រោមក្នុងភូមិភាគនិរតី និងពាយ័ព្យ[60] និងបានបង្ហាញភស្តុតាងនៃការរៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រក្នុងស្រុកស្ថិតក្រោមការគ្រប់គ្រង ឬសិទ្ធិអំណាចរបស់ យឹម ទិត្យ អ៊ឹម ចែម និង អោ អាន[61] និងបានដាក់ភស្តុតាងបន្ថែមនៃឧក្រិដ្ឋកម្មដែលប្រហែលជាត្រូវបានប្រព្រឹត្តនៅវត្តតាមាក់ក្នុងអំឡុងពេលដែល អោ អាន បម្រើការជាលេខាតំបន់ ៤១ នៃភូមិភាគកណ្តាល[62] និងសេចក្តីបំភ្លឺអំពីទីតាំងដែលសហចៅក្រមស៊ើបអង្កេតគប្បី

---

[59] រឿងក្តី ០០៤ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីទីអន្តរជាតិអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ D1/1។

[60] រឿងក្តី ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មតំបន់ ១ និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ D65។

[61] រឿងក្តី ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ និងអំពើហិង្សាលើផ្លូវភេទ និងយេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ D191។

[62] រឿងក្តី ០០៤ ការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធទៅនឹងវត្តតាមាក់ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខD254/1។

ស៊ើបអង្កេតលើការរៀបការដោយបង្ខំដែលអាចត្រូវបានប្រព្រឹត្តឡើងក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ[63] ។

7. ដូចក្នុងរឿងក្តី ០០៣ ប្រឆាំងនឹង មាស មុត និងរឿងក្តី ០០៤/២ ប្រឆាំងនឹង អោ អាន រឿងក្តី ០០៤ បច្ចុប្បន្នប្រឆាំងនឹង យឹម ទិត្យ ស្ថិតក្រោមការខ្វែងយោបល់គ្នាជាសម្ងាត់ជាបន្តបន្ទាប់រវាងសហចៅក្រម ស៊ើបអង្កេត (ដែលបានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និង ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧)[64]។ ពុំមានការខ្វែងយោបល់គ្នាណាមួយត្រូវបាន បញ្ជូនទៅអង្គបុរេជំនុំជម្រះ និងនៅតែសម្ងាត់រហូតដល់បច្ចុប្បន្ន។

8. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ ពី ការរំលោភបំពានលើមាត្រា ៥០១ និង ៥០៦ (មនុស្សឃាតគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បទ ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩[65]។ យឹម ទិត្យ និងសហមេធាវីការពារក្តីរបស់គាត់ពុំបានលើកអំណះអំណាងក្នុងការបង្ហាញខ្លួន លើកដំបូង[66]។

9. ជៀសវាងការលើកប្រវត្តិនីតិវិធីច្រំដែល យើងគប្បីពិនិត្យលើសេចក្តីសម្រេចពាក់ព័ន្ធ និងការខ្វែង យោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង និងចៅក្រម BOHLANDER ដែលជាចៅក្រម អន្តរជាតិទីបួនមកកាន់តំណែងក្នុងការិយាល័យនៃសហចៅក្រមស៊ើបអង្កេត។ អាចនិយាយបានថា រាល់ការ ខ្វែងយោបល់គ្នារវាងចៅក្រមទាំងពីរនៅតែជាការសម្ងាត់ និងពុំដែលបញ្ជូនទៅមុខអង្គបុរេជំនុំជម្រះឡើយ។

---

[63] រឿងក្តី ០០៤ ការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងតំបន់ ១ និង ៤ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ D272/1។

[64] *សូមមើល* រឿងក្តី ០០៤ ដីកាដំណោះស្រាយ ឯកសារលេខ D382 ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ("ដីកាបញ្ជូនរឿងទៅជំនុំ ជម្រះ (D382)") កថាខណ្ឌ ៣, ៧, ២១។ រឿងក្តី ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់រឿងក្តីប្រឆាំងនឹង យឹម ទិត្យ ឯក សារលេខ D381 ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ("ដីកាសម្រេចលើកលែងចោទប្រកាន់(D381)") កថាខណ្ឌ ១៣។

[65] រឿងក្តី ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ D281 ("កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ (D281)")។

[66] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ (D281)។

10. ក្នុងអំឡុងពេលនៃការស៊ើបអង្កេត ការចោទប្រកាន់មួយចំនួនត្រូវបានបដិសេធចោល[67] ហើយបទចោទ និងទម្រង់នៃការទទួលខុសត្រូវបានកែប្រែដោយចៅក្រម BOHLANDER[68]។

11. ចុងក្រោយ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ដោយអនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង[69]។ នៅថ្ងៃដដែល ចៅក្រម BOHLANDER បានកាត់បន្ថយវិសាលភាពបន្ថែមទៀតនៃកិច្ចស៊ើបសួរដោយបានដកចេញនូវអង្គហេតុដែលរងការចោទប្រកាន់មួយចំនួន ដោយអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង[70]។

12. នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងលើកទីពីរ

---

[67] រឿងក្តី ០០៤ សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមនៃការទទួលខុសត្រូវតាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ D342 ("រឿងក្តី ០០៤ សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមនៃការទទួលខុសត្រូវតាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន (D342)")។ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧ ឯកសារលេខ D349 ("សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង (D349)")។ សេចក្តីជូនដំណឹងយោងតាមវិធាន ៦៦ស្ទួន(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារលេខ D354 ("សេចក្តីជូនដំណឹងយោងតាមវិធាន ៦៦ស្ទួន(២) នៃវិធានផ្ទៃក្នុង (D354)")។

[68] រឿងក្តី ០០៤ ដីកាសម្រេចកែប្រែបទចោទប្រឆាំងនឹង យឹម ទិត្យ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារលេខ D350។ ការជូនដំណឹងអំពីដីកាសម្រេចកែប្រែបទចោទប្រឆាំងនឹង យឹម ទិត្យ ឧបសម្ព័ន្ធ ១ ភ្ជាប់ទៅនឹងដីកាសម្រេចកែប្រែបទចោទ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារលេខ D350.1។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមនៃការទទួលខុសត្រូវតាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ ឯកសារលេខ D342។

[69] រឿងក្តី ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង យឹម ទិត្យ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារលេខ D358។

[70] រឿងក្តី ០០៤ ដីកាសម្រេចកាត់បន្ថែមវិសាលភាពនៃកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ឯកសារលេខ D359។ *សូមមើលផងដែរ* រឿងក្តី ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងទៅនឹងការចោទប្រកាន់នីមួយៗ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារលេខ D302/3។ រឿងក្តី ០០៤ សេចក្តីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមនៃការទទួលខុសត្រូវតាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន (D342)។ រឿងក្តី ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង (D349)។ រឿងក្តី ០០៤ វិធាន ៦៦ស្ទួន (២) (D354)។

ស្ដីពីការបញ្ចប់កិច្ចស៊ើបសួរលើ យឹម ទិត្យ[71]។

13. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីនៃរឿងក្ដី ០០៤/២ ថា ខ្លួនបានពិចារណាចេញដីកាដំណោះស្រាយផ្សេងគ្នា និងផ្ទុយគ្នាដែលត្រូវបានអនុញ្ញាតជាទូទៅដោយច្បាប់ជាធរមាន[72]។ ភាគីនៃរឿងក្ដី ០០៤ ត្រូវបានជូនដំណឹងអំពីសេចក្ដីសម្រេចនេះ ដែលក្រោយមកត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ[73]។

14. នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿង ០០៤ ទៅសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយបានអញ្ជើញសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ដាពរក្នុងរយៈពេលបីខែ[74]។

15. នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ដាពរស្នើសុំលើកលែងចោទប្រកាន់រាល់បទចោទប្រឆាំងនឹង យឹម ទិត្យ[75]។ សហព្រះរាជអាជ្ញាអន្តរជាតិក្នុងដីកាសន្និដ្ឋានស្ដាពរចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨ បានស្នើសុំឱ្យធ្វើការចោទប្រកាន់ យឹម ទិត្យ និងបញ្ជូនទៅជំនុំជម្រះ[76]។ នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ សហមេធាវីការពារក្ដី យឹម ទិត្យ បានដាក់សារណាតបទៅ

---

[71] រឿងក្ដី ០០៤ សេចក្ដីជូនដំណឹងលើកទីពីរអំពីការបិទកិច្ចស៊ើបសួរ យឹម ទិត្យ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D368 (“សេចក្ដីជូនដំណឹងលើកទីពីរអំពីការបិទកិច្ចស៊ើបសួរ (D368)”)។

[72] សំណុំរឿងលេខ ០០៤/២/០៧-កញ្ញា-២០០៩-អ.វ.ត.ក./ក.ស.ច.ស (“រឿងក្ដី ០០៤/២”) ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ថ្ងៃទី ១៨ ខែ កញ្ញ ឆ្នាំ ២០១៧ ឯកសារលេខ D355/1 (“ដីកាសម្រេចលើសំណើបន្ទាន់ពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1)”) កថាខណ្ឌ ១៣ ដល់ ១៦។

[73] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១៣។

[74] រឿងក្ដី ០០៤ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១៨ ឯកសារលេខ (៤) D378។

[75] រឿងក្ដី ០០៤ ដីកាសន្និដ្ឋានស្ដាពរពាក់ព័ន្ធនឹង យឹម ទិត្យ យោងតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារលេខ D378/1។

[76] រឿងក្ដី ០០៤ ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារលេខ D378/2។

នឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ដោយស្នើសុំលើកលែងចោទប្រកាន់លើ យឹម ទិត្យ[77]។

16. សហចៅក្រមស៊ើបអង្កេតបានចុះកំណត់ត្រានៃការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការចេញដីកាផ្សេងគ្នា និងផ្ទុយគ្នានៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៩[78]។ ការខ្វែងយោបល់គ្នានេះពុំត្រូវបានបញ្ជូនទៅមុខអង្គបុរេជំនុំជម្រះឡើយ។ ដំណើររឿងដូចគ្នានេះបានកើតឡើងក្នុងរឿងក្ដីពាក់ព័ន្ធនឹង អោ អាន និង មាស មុត។

17. សារៈសំខាន់នៃមតិជំទាស់នេះគឺថា នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា។ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ដោយលើកលែងការចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ និងរាល់បទចោទទាំងអស់ដោយផ្អែកលើមូលដ្ឋានថា គាត់ពុំស្ថិតក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. ដែលជា"មេដឹកនាំជាន់ខ្ពស់" ឬស្ថិតក្នុងចំណោមអ្នក"ដែលទទួលខុសត្រូវខ្ពស់បំផុត"[79]។ ចៅក្រម យូ ប៊ុនឡេង ពន្យល់ថា៖

> យឹម ទិត្យ អាចមានឋានៈស្រដៀងគ្នានឹង អោ អាន និង មាស មុត និងខ្ពស់ជាង ឌុច មែន ប៉ុន្តែជាសត្យានុម័ត កម្មាភិបាលកាន់តំណែងធំខ្លះមិនប្រាកដថា មានអំណាចច្រើននោះទេ។ [...] យឹម ទិត្យ [...] មិនមានអ្នកក្រោមបង្គាប់ជាក់លាក់ច្បាស់លាស់ដែលនេះផ្ទុយពី ឌុច ដែលគ្រប់គ្រងមន្ទីរសន្តិសុខមជ្ឈិម (ស-២១) បានរចនាសម្ព័ន្ធដឹកនាំក្រោមបង្គាប់យ៉ាងជាក់លាក់ដែលធ្វើឱ្យ ឌុច ចូលរួមសកម្មភាពឧក្រិដ្ឋយ៉ាងសកម្មបង្កឱ្យមនុស្សជាតិ ១២.០០០ (មួយម៉ឺនពីរពាន់) នាក់ស្លាប់ ដោយអំពើផ្ទាល់ និងប្រយោលរបស់គាត់ តាមរយៈការដឹកនាំ ចាត់ចែង និងគ្រប់គ្រងមន្ទីរសន្តិសុខប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលស្ទើរពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។
>
> ជាសរុប ការចូលរួមក្នុងទីតាំងបទល្មើសខាងលើនេះ ត្រឹមតែជាការចូលរួមដឹងឮ ជាការចូលរួមមិនសកម្ម គ្មានគំនិតផ្តួចផ្តើម ឬចូលរួមក្នុងកម្រិតនៃកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាល

---

[77] រឿងក្ដី ០០៤ ការឆ្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ D378/5។

[78] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ២១។ ដីកាសម្រេចលើកលែងចោទប្រកាន់ (D381) កថាខណ្ឌ ១៣។

[79] ដីកាសម្រេចលើកលែងចោទប្រកាន់ (D381)។

កម្រិតតំបន់ ឬភូមិភាគជាច្រើនរូបទៀត។ វាជាការចូលរួមអនុវត្តការងារតាមគោលនយោបាយបក្សដែលត្រូវតែគោរព និងធ្វើតាម។ យឹម ទិត្យ មិនមានកម្មាភិបាលក្រោមបង្គាប់ជាក់លាក់ចូលរួមអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងមានវិសាលភាពទូលំទូលាយឡើយ។ ដោយឡែក គាត់កាន់តួនាទីក្នុងអំឡុងពេលដ៏ខ្លីក្នុងភូមិភាគពាយ័ព្យ។ ការចូលរួមដូចនេះ មិនស្ថិតក្នុងលក្ខណៈវិនិច្ឆ័យនៃជន"ទទួលខុសត្រូវខ្ពស់បំផុត"របស់ជនត្រូវចោទដែលផ្តោតជាចម្បងទៅលើសកម្មភាពចូលរួមជាក់ស្តែង និងដោយផ្ទាល់ មិនសំដៅលើឋានៈជាចម្បង។

យើងឃើញថា មិនមានភស្តុតាងដែលអាចឱ្យយើងរកឃើញថា យឹម ទិត្យ គឺជាមេដឹកនាំជាន់ខ្ពស់ ឬក៏ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ អាស្រ័យហេតុនេះ អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើគាត់ឡើយ[80]។

18. ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញថា យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការនៃរូបបុគ្គលរបស់ អ.វ.ត.ក. ដោយសារជាបុគ្គលម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មសម័យខ្មែរក្រហម និងបានចេញដីកាដំណោះស្រាយសម្រេចចោទប្រកាន់ពីបទប្រល័យពូជសាសន៍លើខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសក្នុងស្រុកតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[81]។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញថា បទចោទមួយចំនួនពុំមានមូលដ្ឋានគាំទ្រ និងត្រូវបដិសេធចោល[82]។ ចៅក្រម BOHLANDER ពន្យល់ថា៖

បើនិយាយអំពីមុខតំណែងផ្លូវការរបស់គាត់ គាត់បានឡើងឋានៈយ៉ាងឆាប់រហ័សពីមុខតំណែងជាអនុលេខាស្រុកនៅភូមិភាគនិរតី ទៅជាអនុលេខភូមិភាគ ហើយរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់ប្រហែលជាបានឡើងឋានៈជាលេខាភូមិភាគពេញលេញនៃភូមិភាគពាយ័ព្យ។ ជាងនេះទៀត គាត់បានធ្វើជាលេខាតំបន់នៅតាមតំបន់មួយចំនួននៅក្នុងភូមិភាគពាយ័ព្យ។ ហេតុដូច្នេះ សិទ្ធិអំណាចរបស់គាត់នៅក្រោម ប.ក.ក. លាតសន្ធឹងយ៉ាងឆ្ងាយ

---

80 ដីកាសម្រេចលើកលែងចោទប្រកាន់ (D381) កថាខណ្ឌ ៦៨២-៦៨៤។

81 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៤៥៥-៤៦៣។

82 សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ចប់កិច្ចស៊ើបសួរជាផ្លូវការលើអង្គហេតុដែលត្រូវបានដកចេញក្នុងសេចក្តីសម្រេចតាមវិធាន ៦៦ ស្ទួននៃវិធានផ្ទៃក្នុង និងចេញដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងផ្នែកខ្លះ បដិសេធបទចោទមួយចំនួនប្រឆាំងនឹង យឹម ទិត្យ។

ទាំងផ្នែកភូមិសាស្ត្រ និងទាំងនៅក្នុងឋានានុក្រម។

មុខតំណែងផ្លូវការរបស់គាត់ និងការឡើងឋានៈលឿនដូចដុំថ្មធ្លាក់ពីលើមេឃ ត្រូវបានគាំទ្រដោយចំណងគ្រួសារយ៉ាងជិតស្និទ្ធរបស់គាត់ ជាមួយកម្មាភិបាលថ្នាក់កំពូលម្នាក់ដែលស្ថិតនៅក្នុងឋានានុក្រម ប.ក.ក. គឺ តាម៉ុក ដែលត្រូវជាបងថ្លៃគាត់។ សូម្បីតែតាំងពីមុនការចូលកាន់តំណែងផ្លូវការនៅភូមិភាគពាយ័ព្យរបស់គាត់ក៏ដោយ ក៏គេបានឃើញគាត់ធ្វើដំណើរជាមួយតាម៉ុក ទូទាំងភូមិភាគ និងការជួបប្រជុំជាដើម។ គាត់គឺជាមេបញ្ជាការតាមព្រឹត្តន័យទីពីររបស់តាម៉ុក និងបើតាមភស្តុតាង គាត់ក៏មានសិទ្ធិអំណាចតាមព្រឹត្តន័យទៅលើសកម្មភាពនៅតាមតំបន់មុនៗរបស់គាត់ផងដែរ ទោះបីជាបានទៅភូមិភាគពាយ័ព្យហើយក៏ដោយ។

សូម្បីតែនៅក្រោយការកាត់បន្ថយទីតាំងឧក្រិដ្ឋកម្មជិតពាក់កណ្ដាលពីបញ្ជីដើម ដែលផ្អែកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយអនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុងហើយក៏ដោយ គឺគាត់នៅតែស្ថិតក្រោមការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាជាង ២០ ទីតាំងដែរ។

ភាពលេចធ្លោពាក់ព័ន្ធនឹងចំណុចនេះគឺការចូលរួមប្រព្រឹត្ត និងការរៀបចំរបស់គាត់ក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម នៅក្នុងតំបន់ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គាត់ ដែលចំនួនមនុស្សស្លាប់ តាមការវាយតម្លៃយ៉ាងតិចផ្អែកលើភស្តុតាងបានរកឃើញក្នុងការស៊ើបអង្កេត មានពីចន្លោះរាប់ពាន់នាក់ [...] ដូចនៅក្នុងរឿងក្ដី ០០៤/២ និង ០០៣ អង្គហេតុនេះតែងអាចដាក់គាត់បានយ៉ាងសមស្របឱ្យស្ថិតក្នុងវិសាលភាពនៃយុត្តិធិការលើរូបបុគ្គល។

ក្រៅពីបទប្រល័យពូជសាសន៍ដែលកំណត់គោលដៅលើខ្មែរក្រោម ជនស៊ីវិលដទៃទៀត និងកម្មាភិបាលកបក្បកុម្មុយនីស្តកម្ពុជាត្រូវបានធ្វើឱ្យទៅជាជនរងគ្រោះក្រោម និងដោយ យឹម ទិត្យ ក្នុងចំនួនរាប់ម៉ឺននាក់ ផ្អែកលើចក្ខុវិស័យនយោបាយដឹកនាំខុស និងរើសវាយ តាមរយៈការសម្លាប់ជាបន្តបន្ទាប់ និងក្នុងទ្រង់ទ្រាយធំ ដោយមានការរៀបចំយ៉ាងល្អ ព្រមទាំងការប្រព្រឹត្តដ៏ឃោរឃៅ និងអមនុស្សធម៌តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង និងពលកម្មយ៉ាងវេទនាក្នុងលក្ខខណ្ឌមិនអាចនិយាយចេញ នៅតាមបណ្ដាមន្ទីរសន្តិសុខ និងការដ្ឋានការងារ។ កម្រិតនៃភាពមាក់ងាយដ៏អមនុស្សធម៌ដែលបានបង្ហាញឱ្យឃើញនៅតាមបណ្ដាទីតាំងទាំងនេះ និង

កម្រិតនៃភាពអមនុស្សធម៌របស់ជនទាំងឡាយដែលកាន់ការងារនៅទីនោះ គឺប្រៀបបានទៅនឹងការភ័យរន្ធត់នៃជំរុំប្រមូលផ្តុំណាស៊ីនៅក្នុងប្រទេសអាល្លឺម៉ង់។

ការប្រមាថចំពោះជម្រើសនៃជីវិតសម្រាប់មនុស្សម្នាក់ៗក្នុងកម្រិតដូចគ្នានេះ នឹងជាពិសេសស្វ័យភាពក្នុងការសម្រេចចំពោះទំនាក់ទំនងផ្លូវភេទ ត្រូវបានអនុវត្តតាមរយៈគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ មនុស្សប្រុស និងស្រីត្រូវបានដាក់ឱ្យស្ថិតនៅក្រោម យឹម ទិត្យ និងអ្នកដែលគាត់បានសហការជាមួយចំពោះការពិសោធន៍សង្គមដែលគួរឱ្យខ្ពើមរបស់ ប.ក.ក. ក្នុងការកាត់បន្ថយបន្ថោកប្រពៃណីរៀបអាពាហ៍ពិពាហ៍ ឱ្យមកនៅត្រឹមជាឧបករណ៍សម្រាប់ឃោសនាចំពោះមនុស្ស និងដើម្បីបង្កើនចំនួនប្រជាជនកម្ពុជា ដោយគ្មានអារម្មណ៍ជាមនុស្ស ក្រៅពីបង្កើតការភ័យខ្លាច ភាពស្អប់ខ្ពើម កំហឹង និងការនាំមកនូវភាពអាក់អន់ចិត្តចំពោះគ្នាតែប៉ុណ្ណោះ[83]។

19. នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៩ អង្គបុរេជំនុំជម្រះ បានបង្គាប់ភាគីឱ្យដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤ ក្នុងរយៈពេល ១៤ ថ្ងៃក្រោយពីការជូនដំណឹងនូវសំណៅបកប្រែដីកាដំណោះស្រាយទាំងពីរនេះ[84]។

20. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ និងថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០ ភាគីទាំងអស់ បានដាក់បណ្តឹងឧទ្ធរណ៍ និងការឆ្លើយតបទៅនឹងដីកាដំណោះស្រាយផ្ទុយគ្នានោះ។ អំណះអំណាងរបស់សហព្រះរាជអាជ្ញាជាតិសម្រាប់ការជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅដែលចាប់តាំងពីឆ្នាំ ២០០៨/២០០៩។ គាត់បានលើកហេតុផលថា ជាទូទៅ អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានប្រមូលផ្តុំនៅក្នុង

[83] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៩៩៣ -៩៩៨។

[84] រឿងក្តី ០០៤ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមពេលវេលាសម្រាប់កាលបរិច្ឆេទនៃការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០៤ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ D381/3 និង D382/3។ *សូមមើលផងដែរ* រឿងក្តី ០០៤ សំណើរបស់ យឹម ទិត្យ សុំបន្ថែមពេលវេលានៃកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ D381/1 និង D382/1។ រឿងក្តី ០០៤ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមពេលវេលានៃកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D381 & D382 (D381/1 & D382/1) ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ D381/2 និង D382/2។

ដៃរបស់គណៈអចិន្ត្រៃយ៍ដែលជាអ្នកដឹកនាំរដ្ឋ។ តាម៉ុក ដែលដើរតួយ៉ាងសំខាន់ក្នុងភូមិភាគពាយ័ព្យ និង មជ្ឈិម គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍។ យឹម ទិត្យ ពុំមែនជាសមាជិក និងពុំមែនជាមេដឹកនាំភូមិភាគ ឬ សមាជិកនៃគណៈអចិន្ត្រៃយ៍។ គាត់ច្បាស់ណាស់ពុំមែនជាបុគ្គលដែលត្រូវបានប៉ុនប៉ងធ្វើការចោទប្រកាន់ក្នុង ការចរចាដែលនាំទៅរកការអនុម័តច្បាប់ ឬកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល កម្ពុជា។ គាត់ពុំមែនជាមេដឹកនាំជាន់ខ្ពស់ និងពុំស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ ឧក្រិដ្ឋកម្ម។ ការចោទប្រកាន់លើមេដឹកនាំជាន់ខ្ពស់ក្នុងសំណុំរឿង ០០២ ជាការគ្រប់គ្រាន់សម្រាប់ផ្តល់ យុត្តិធម៌ដល់ជនរងគ្រោះ។ សហព្រះរាជអាជ្ញាជាតិបានស្នើសុំអង្គបុរេជំនុំជម្រះលើកលែងការចោទប្រកាន់ លើ យឹម ទិត្យ ដោយសារការខ្វះយុត្តាធិការលើរូបបុគ្គល[85]។

21. សហមេធាវីការពារក្តី យឹម ទិត្យ ក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបានលើកឡើង ថា ដីកាដំណោះស្រាយផ្សេងគ្នា និងផ្ទុយគ្នាគប្បីត្រូវបានបដិសេធចោទប្រកាន់ទាំងពីរ[86] និងបានជំទាស់ទៅ នឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា យឹម ទិត្យ ស្ថិតក្នុងចំណោមអ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត"ចំពោះឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[87]។

22. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ លើកឡើងថា ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើនដែលបណ្តាល ឱ្យមានកំហុស"ជាក់ច្បាស់"ក្នុងការយល់ឃើញដែលថា យឹម ទិត្យ ពុំស្ថិតក្រោមយុត្តាធិការលើរូបបុគ្គល របស់ អ.វ.ត.ក.។ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំអង្គបុរេជំនុំជម្រះ បដិសេធដីកាសម្រេចលើក លែងចោទប្រកាន់ និងបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំ

---

[85] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1)។ *សូមមើលផងដែរ* រឿងក្តី ០០៤ សំណើរបស់សហព្រះរាជអាជ្ញាជាតិសុំដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ជាភាសាខ្មែរមុន ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ D382/7។ រឿងក្តី ០០៤ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាជាតិសុំដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិជាភាសាខ្មែរមុន ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ D382/8។

[86] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយពីរ) (D381/18 & D382/21)។

[87] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22)។

ជម្រះ[88]។

23. ដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សារណានៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[89] ដោយបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការសន្និដ្ឋានថា យឹម ទិត្យ ពុំស្ថិតក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក. និងជាជម្រើសថា ប្រសិនបើអង្គបុរេជំនុំជម្រះពុំអាចទទួលបានសម្លេងភាគច្រើនលើសលុបទេ ក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. តម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង[90]។

24. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១ អង្គបុរេជំនុំជម្រះ បានចេញសេចក្ដីពិចារណារបស់ខ្លួន ស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[91]។ ចៅក្រមទាំងប្រាំរូបបានបញ្ជាក់ជំហររឹងមាំមិនយល់ស្របជាមួយនឹងចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាដែលត្រូវបានចាត់ទុកថាជាការធ្វើឱ្យខូចដល់គោលការណ៍គ្រឹះរបស់ អ.វ.ត.ក. និងជាការខុសច្បាប់។ ទោះជាយ៉ាងណាក្ដី ចៅក្រមអង្គបុរេជំនុំជម្រះបានបន្តកំណត់លើបញ្ហាថាតើ ដីកាដំណោះស្រាយនេះមានសុពលភាព ដែរឬយ៉ាងណា។ ចៅក្រមជាតិបានអនុម័តតាមអំណះអំណាងរបស់សហព្រះរាជអាជ្ញាជាតិ និងបានគាំទ្រសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់នោះ។ ចៅក្រមជាតិបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត មានឋានៈស្មើគ្នា និងបានតម្កល់សុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ និងថា ខុសគ្នាពីរឿងក្ដីប្រឆាំងនឹង មាស មុត ដែលចៅក្រមជាតិបានយល់ឃើញថា ដីកាដំណោះស្រាយទាំងពីរមានសុពលភាពដូចគ្នា ម្ដងនេះចៅក្រមជាតិពុំមានការអធិប្បាយអំពីឋានៈនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ សំអាងហេតុភាគច្រើនមាននៅក្នុងសេចក្ដីពិចារណាទំព័រទី៧ ត្រូវបានធ្វើឡើងផ្អែកលើអំណះអំណាងដដែល ៗដូចក្នុងរឿងក្ដី ០០៣ និង ០០៤/២ ថា នេះជាកិច្ចស៊ើបសួរខុសច្បាប់ចាប់តាំងពីឆ្នាំ ២០០៨ និងបន្ថែមថា សុខ អាន បានបញ្ជាក់នៅមុខសភាតំណាងជាតិថា មានតែបុគ្គលប្រាំនាក់ប៉ុណ្ណោះដែលត្រូវធ្វើការចោទ

---

[88] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19)។

[89] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D381/20)។

[90] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D381/20)។

[91] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D381/45 និង D382/43 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១។

ប្រកាន់ជាមេដឹកនាំជាន់ខ្ពស់[92]។ ចៅក្រមជាតិពុំបានពិចារណាលើទឡ្ហីករណ៍ណាមួយនៃបណ្ដឹងឧទ្ធរណ៍របស់ភាគីនានា និងពុំបានបង្កើតការយល់ឃើញលើសុពលភាពនៃដីកាដំណោះស្រាយដែលតម្កល់ដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ។

25. ចៅក្រមអន្តរជាតិពិចារណាទឡ្ហីករណ៍នីមួយៗនៃបណ្ដឹងឧទ្ធរណ៍ និងបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានបដិសេធសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់"ផ្អែកលើលក្ខណៈនៃដីកានេះដែលពុំត្រូវបានអនុញ្ញាត"[93]។ ផ្អែកតាមការយល់ឃើញពីដំបូងរបស់អង្គជំនុំជម្រះតុលាការកំពូលបង្ហាញថាការពិនិត្យដោយមានភាពអល់អែកលើខ្លឹមសារដីកាដំណោះស្រាយ គឺជាការអនុវត្តដោយឥតចាំបាច់បន្ទាប់ពីមានការយល់ឃើញជាឯកច្ឆន្ទថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេត ជាការខុសច្បាប់ និងមានភាពចាំបាច់តិចតួចក្នុងការពិនិត្យលើការពិចារណាដែលពុំស៊ីសង្វាក់គ្នាផ្នែកខ្លឹមសារបន្ថែមទៀតនោះ[94]។

26. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តដំណើរការនៃការបញ្ជូនសេចក្ដីសម្រេចខុសប្លែកពីធម្មតាមកចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់"បណ្ដឹងសាទុក្ខស្ដីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនរឿងក្ដី ០០៤ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ក.ក."[95]។

27. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១ សហមេធាវីការពារក្ដីបានដាក់សំណើរបស់" យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតបញ្ចប់ភ្លាមៗ បោះត្រា និង រក្សាទុកក្នុងបណ្ណសារនូវសំណុំរឿង ០០៤"[96]។

28. នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២១ សហមេធាវីការពារក្ដី យឹម ទិត្យ បានដាក់សារណាតបទៅនឹង

---

[92] ការពិភាក្សាលើចំណុចទាំងនេះ *សូមមើល* សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្ដី ០០៣ (3/1/1/1) មតិជំទាស់របស់ចៅក្រម Maureen Harding Clark កថាខណ្ឌ ៩៣-១០៩។

[93] សេចក្ដីពិចារណារឿងក្ដី ០០៤ កថាខណ្ឌ ១៧៣, ១៧៥-១៧៦។

[94] សេចក្ដីរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០៤/២ (004/2/1/1/2) កថាខណ្ឌ ៥៣។

[95] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

[96] សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតបញ្ចប់ភ្លាមៗ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនូវសំណុំរឿង ០០៤ ឯកសារ D386 ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១។

សំណើ[97]។ នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតបទៅនឹងសារណាតបរបស់សហមេធាវីការពារក្ដី[98]។

29. នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១ សហចៅក្រមស៊ើបអង្កេត តាមរយៈ អ៊ីម៉ែល បានជូនដំណឹងភាគីនៃសំណុំរឿង ០០៣ និង ០០៤ ថា៖

> សហចៅក្រមស៊ើបអង្កេត (CIJs) ដោយស្របតាមទស្សនៈដែលបានលើកឡើងរបស់ខ្លួនស្ដីពីយុត្តាធិការសេសសល់ដែលខ្លួនមាន ជូនដំណឹងភាគីនៃសំណុំរឿង ០០៣ និង ០០៤ ថា ខ្លួននឹងមិនបន្តសម្រេចទាក់ទងទៅនឹងបញ្ហាថាតើ ត្រូវបញ្ចប់ បោះត្រា និងរក្សាទុកក្នុងបណ្ណសារនូវសំណុំរឿងនេះ រហូតទាល់តែអង្គជំនុំជម្រះតុលាការកំពូល (SCC) បានសម្រេចក្នុងកិច្ចដំណើរការនីតិវិធីនេះដែលបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះ។
>
> បន្ថែមលើនេះ ប្រសិនបើ SCC ពុំសម្រេចលើអង្គសេចក្ដី ហើយសំណុំរឿងបង្វិលទៅ សហចៅក្រមស៊ើបអង្កេត (CIJs) ការអះអាងថ្មីៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ICP) ក្នុងសំណុំរឿង ០០៤ ដែលបានចាត់ទុកសហចៅក្រមស៊ើបអង្កេត (CIJs) មានភាពលម្អៀងនោះ ហាក់បីដូចជាចង់បញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិ មានបំណងដាក់បណ្ដឹងជំទាស់ចៅក្រមតាមវិធាន ៣៤ នៅមុខអង្គបុរេជំនុំជម្រះក្នុងស្ថានការណ៍នោះ។ ក្នុងករណីចាំបាច់ស្ថានការណ៍ដូចគ្នានេះនឹងអនុវត្តចំពោះសំណុំរឿង ០០៣[99]។

## II. កំណត់សម្គាល់បឋម

30. នេះជាគោលការណ៍ទូទៅដែលថា រឿងក្ដីនីមួយៗត្រូវតែទទួលបានចំណាត់ការស្មើគ្នា។ បើទោះបី

---

[97] សារណាតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ឯកសារលេខ 2/1 ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២១ (“សារណាតបរបស់ យឹម ទិត្យ”)។

[98] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសារណាតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ឯកសារលេខ 2/1/1 ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០២១។

[99] សេចក្ដីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតដល់ភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១។

សេចក្តីលម្អិតអង្គហេតុនៃរឿងក្តីនេះ អាចខុសគ្នាពីរឿងក្តី ០០៣ និង ០០៤/២ ក៏ដោយ ក៏ប៉ុន្តែប្រវត្តិនីតិវិធី និងគោលការណ៍ច្បាប់មានលក្ខណៈដូចគ្នា។ រឿងក្តីទាំងបីនេះទទួលរងការប៉ះពាល់ដោយសារសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំមានមូលដ្ឋានត្រឹមត្រូវ និងពុំអាចយល់បានសមស្រប ដោយសារការខកខានក្នុងការដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត និងខកខានក្នុងការផ្តល់ដំណោះស្រាយច្បាស់លាស់ថាត្រូវជំនុំជម្រះ ឬត្រូវបញ្ចប់។ និយាយម្យ៉ាងទៀតបានថា អង្គបុរេជំនុំជម្រះខកខានក្នុងការផ្តល់សេចក្តីសម្រេចត្រឹមត្រូវផ្នែកច្បាប់ ដែលរឿងក្តីនេះអាចនឹងត្រូវលើកលែងចោទប្រកាន់ ឬយន្តការស្វ័យប្រវត្តិអាចត្រូវអនុវត្ត។ ការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការសម្រេចបានបង្កើតឱ្យភាពជាប់គាំងផ្លូវច្បាប់[100]។ ផ្អែកតាមកាលៈទេសៈធម្មតា សេចក្តីសម្រេចនេះនឹងត្រូវបានបដិសេធចោលដោយសារការខកខានដោះស្រាយបញ្ហាពាក់ព័ន្ធដែលនាំទៅរកភាពទាល់ច្រក ដោយសារការចេញសំអាងហេតុដែលពុំសមស្រប និងការបង្កើតសម្រេចមួយដែលពុំអាចបញ្ចប់ ឬបន្តដំណើររឿងក្តីបាន។ ក្នុងករណីបែបនេះ អង្គជំនុំជម្រះនេះអាចបង្គាប់ឱ្យមានការពិចារណាឡើងវិញដោយអង្គបុរេជំនុំជម្រះលើការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ។ នៅផ្នែកម្ខាងទៀតនៃសេចក្តីសម្រេចដែលពុំសមស្របនេះ គឺថា យឹម ទិត្យ ដែលកើតនៅចុងឆ្នាំ ១៩៣៦ និងត្រូវបានដាក់ឱ្យស្ថិតក្រោមកិច្ចស៊ើបសួរអស់រយៈពេលយ៉ាងតិច ១២ ឆ្នាំ ជាមួយនឹងអ្នកដទៃទៀតក្នុងរឿងក្តីប្រហាក់ប្រហែលគ្នានេះ ត្រូវបានដាក់ឱ្យស្ថិតក្រោមការខ្វែងយោបល់គ្នានៃការចោទប្រកាន់ចាប់តាំងពីឆ្នាំ ២០០៩។ បើទោះបីជា យឹម ទិត្យ ពុំដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពក្នុងអំឡុងពេលនៃការពន្យារពេលនេះក៏ដោយ ក៏បច្ចុប្បន្នគាត់មានអាយុ ៨៥ ឆ្នាំហើយ ដែលនេះគឺជាចំណុចគប្បីពិចារណា។ ការអះអាងដូចគ្នានេះក៏អនុវត្តចំពោះសាក្សីជាច្រើន ដើមបណ្តឹងរដ្ឋប្បវេណី (និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) និងជនរងគ្រោះដែលបច្ចុប្បន្នមានអាយុជាង ៤០ ឆ្នាំ ហើយរឿងក្តីនេះនៅបន្តរយៈពេលច្រើនឆ្នាំទៅមុខទៀតមិនដឹងទីបញ្ចប់ពេលណា។

31. ការខ្វែងយោបល់គ្នាលើបញ្ហាយុត្តាធិការថាតើ តួនាទីរបស់ យឹម ទិត្យ ជាកម្មាភិបាលខ្មែរក្រហមបានធ្វើឱ្យគាត់ជាបុគ្គលម្នាក់ដែល“ទទួលខុសត្រូវខ្ពស់បំផុត”សម្រាប់ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ដែរឬយ៉ាងណា និងបញ្ហាថាតើ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានកម្រិតត្រឹមតែការជំនុំជម្រះសំណុំរឿង ០០១ និង ០០២ ដែរ ឬយ៉ាងណា គឺជាការខ្វែងយោបល់គ្នាសំខាន់

[100] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី ០០៣ (3/1/1/1) មតិជំទាស់របស់ចៅក្រម Maureen Clark កថាខណ្ឌ ៨៣។

រវាងបុគ្គលិកជាតិ និងអន្តរជាតិនៅ អ.វ.ត.ក.។ ការវិវឌ្ឍន៍នៃរឿងក្តីទាំងបី (០០៣ ០០៤ និង ០០៤/២) បានបញ្ឈប់ដំណើរនៅមុខអង្គបុរេជំនុំជម្រះ ដែលផ្អែកតាមព័ត៌មានបង្ហាញបច្ចុប្បន្នឃើញថា ទីបញ្ចប់ រឿងក្តីនេះជាប់គាំងពុំមានច្រកចេញ។ ការពិភាក្សាពេញលេញអំពីការខ្វែងយោបល់គ្នាដែលមើលទៅពុំអាចសម្របសម្រួលបានរវាងបុគ្គលិកជាតិ និងអន្តរជាតិត្រូវបានរៀបរាប់លម្អិតនៅក្នុងមតិជំទាស់របស់ខ្ញុំក្នុងសំណុំរឿង ០០៣[101]។ ការពិតនោះគឺថា អង្គបុរេជំនុំជម្រះ គឺជាវេទិកាដែលវិវាទរវាងសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ត្រូវបានដោះស្រាយ ប៉ុន្តែផ្ទុយទៅវិញពុំមានសេចក្តីសម្រេចត្រូវបានធ្វើឡើងដែលភាពច្បាស់លាស់ ឬការណែនាំឱ្យរឿង ០០៣ ០០៤ និង ០០៤/២ ត្រូវបន្តទៅជំនុំជម្រះ ឬបញ្ចប់ដោយសារដីកាសម្រេចលើកលែងចោទប្រកាន់។ បន្ថែមលើនេះ ពុំមានសេចក្តីសម្រេចត្រូវបានធ្វើឡើងដោយមានការផ្តល់នូវការយល់ឃើញដែលអនុញ្ញាតយន្តការស្វ័យប្រវត្តិត្រូវប្រតិបត្តិការឡើយ។

## III. ច្បាប់ជាធរមាន

32. មាត្រា ១ និង ២ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងមាត្រា ១ កិច្ចព្រមព្រៀង អ.វ.ត.ក. ចែងថា គោលបំណងចម្បងរបស់តុលាការនេះ គឺនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសក្នុងអំឡុងពេលនៃចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ មានបុគ្គលពីរប្រភេទដែលបានរួមបញ្ចូលច្បាស់លាស់ក្នុងមាត្រាទាំងនេះ។

33. មាត្រា ៩ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា អង្គជំនុំជម្រះតុលាការកំពូលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសម្រេចសេចក្តីចុងក្រោយផង។

34. មាត្រា ១២(២) នៃកិច្ចព្រមព្រៀងចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញត្រូវប្រើប្រាស់យុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរនីតិវិធីសមស្របនៃច្បាប់ ដូចបានកំណត់ក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាគឺភាគី [...]

35. វិធាន នៃវិធានផ្ទៃក្នុង ២១(១) ចែងថា៖

---

[101] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី ០០៣ (3/1/1/1) មតិជំទាស់របស់ចៅក្រម Maureen Clark។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។

36. មតិជំទាស់រឿងក្តី ០០៣ បានរៀបរាប់ពេញលេញនូវដំណើរការនៃការខ្វែងយោបល់គ្នា[102]។ អាចនិយាយបានថា ដំណើរការទាំងនោះតាមធម្មតាពុំត្រូវបានអនុវត្ត ហើយការបំភ្លឺផ្នែកច្បាប់ដែលត្រូវបានគេរំពឹងផ្តល់ដោយអង្គបុរេជំនុំជម្រះដែលផ្អែកលើមូលដ្ឋាននៃការខ្វែងយោបល់គ្នាលើយុត្តាធិការជាសារវ័ន្ត ពុំបានកើតឡើង។ សេចក្តីសម្រេចនោះបិទផ្លូវតវ៉ា។

## IV. **សារណា**

37. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដោយសារការខកខានរបស់អង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ និងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រើប្រាស់យុត្តាធិការរបស់ខ្លួនលើរឿងក្តី ទើបជាការចាំបាច់ដែល អង្គជំនុំជម្រះតុលាការកំពូល ត្រូវប្រើប្រាស់យុត្តាធិការដែលជាឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបញ្ចៀសព្យសនកម្មដែលពុំអាចស្រោចស្រង់បានលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិជាសារវ័ន្តរបស់ភាគីក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌[103]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ប្រសិនបើគ្មានកិច្ចអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល កិច្ចដំណើរការនីតិវិធីនៅតែពុំមានភាពច្បាស់លាស់ ដែលអាចជាយុត្តិនិសេធដោយបានរំលោភបំពានលើអាណត្តិរបស់ អ.វ.ត.ក. និងគោលការណ៍ជាសារវ័ន្ត[104]។

38. ដោយសារអ្វីដែលហាក់បីដូចការពុះពារជម្នះការលំបាកដែលពុំអាចទៅរួច និងការខ្វែងយោបល់គ្នា

[102] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី ០០៣ (3/1/1/1) មតិជំទាស់របស់ចៅក្រម Maureen Clark កថាខណ្ឌ ១០-២៣។

[103] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣២-៣៤។

[104] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៤។

ក្នុងការបកស្រាយមាត្រា ១ និង ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងកិច្ចព្រមព្រៀង និងជួយសង្គ្រោះឱ្យរួចផុតពីសេចក្តីសម្រេចដែលមានវិការៈជាមូលដ្ឋានរបស់អង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីបង្គាប់ឱ្យរឿងក្តីនេះដំណើរការទៅជំនុំជម្រះដោយសារ (១) ដីកាដំណោះស្រាយដែលផ្ទុយគ្នានោះ ពុំត្រូវបានចេញដោយខុសច្បាប់ឡើយ[105] (២) ដីកាដំណោះស្រាយផ្ទុយគ្នានោះមានសុពលភាព បើទោះបីជាមានការចេញការចេញនោះក្នុងពេលដំណាលគ្នានោះជាការខុសច្បាប់ក៏ដោយ[106] (៣) ដីកាបញ្ជូនរឿងទៅជំនុំជម្រះពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប[107] និង (៣) សំណុំរឿង ០០៤ ពុំមែនខុសច្បាប់ឡើយ[108]។

39. ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ដោយសារឋានៈស្មើគ្នា និងឯករាជ្យរបស់សហចៅក្រមស៊ើបអង្កេតដូចបានកំណត់ដោយយន្តការដោះស្រាយការខ្វែងយោបល់គ្នា នេះមានន័យថា ដីកាដំណោះស្រាយផ្ទុយគ្នាត្រូវបានអនុញ្ញាត និងត្រូវបានរំពឹងទុក និងតាមការសន្និដ្ឋាន គឺសម្រាប់អង្គបុរេជំនុំជម្រះដោះស្រាយ[109]។

40. ទីពីរ បើទោះបីជាការចេញដំណាលគ្នានៃដីកាដំណោះស្រាយជាក់ស្តែងគឺជាការខុសច្បាប់ក៏ដោយ ក៏ការបំពេញកិច្ចនោះ គឺជាកំហុសផ្នែកនីតិវិធីដែលធ្វើឱ្យប៉ះពាល់ទាំងស្រុងដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ ការប៉ះពាល់ជាសត្យានុម័ត ឬការរំលោភបំពានលើនីតិវិធី ដែលតម្រូវឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធីឡើយ[110]។ ការបញ្ចប់រឿងក្តីនេះ អាចនឹងពុំសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មការប៉ះពាល់ដល់តម្លៃសង្គមយ៉ាងខ្លាំងក្នុងការរារាំងរឿងក្តីនេះមិនឱ្យបន្តដំណើរការ អត្ថប្រយោជន៍ និងសិទ្ធិរបស់ភាគីទាំងអស់ និងសមាមាត្រនៃសំណងទៅនឹងព្យសនកម្ម[111]។

41. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងដោយសុទិដ្ឋិនិយមបន្តិចថា អង្គបុរេជំនុំជម្រះត្រូវបាន

---

[105] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៦-៤៤។

[106] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤៥-៥១។

[107] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥២-៥៧។

[108] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៨-៧១។

[109] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៦។

[110] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤៥-៤៩។

[111] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៤៦ ៥០-៥១។

តម្រូវឱ្យបញ្ជូនសំណុំរឿងទៅជំនុំជម្រះដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះពុំត្រូវបានច្រានចោលដោយមតិភាគច្រើនលើសលុប[112]។ យន្តការស្វ័យប្រវត្តិ"ជាមូលដ្ឋាន និងឥតប្រែប្រួល"ដែលថា កិច្ចស៊ើបសួរគប្បីបន្តតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងនោះ គឺជា*អាទិភាពគោលការណ៍ច្បាប់ពិសេសដែលគ្រប់គ្រងផ្ទាល់លើកម្មវត្ថុរឿងក្ដីជាក់លាក់ និងមានឧត្តមភាពជាងវិធាន* ៧៧(១៣)(ក)នៃវិធានផ្ទៃក្នុង ដូច្នេះតម្រូវថា ដីកាចោទប្រកាន់ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[113]។

42. ទីបួន សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ មានកំហុសក្នុងការយល់ឃើញថា រឿង ០០៤ ទាំងមូល គឺជាការខុសច្បាប់[114]។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា បើទោះបីជាកិច្ចស៊ើបសួរបឋមជាឯកតោភាគីក៏ដោយ ក៏ត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុង និង ដូច្នេះ ពុំមានវិការៈផ្នែកនីតិវិធីឡើយ[115]។ ការបកស្រាយដែលត្រូវបានអនុម័តដោយចៅក្រមជាតិអង្គបុរេជំនុំជម្រះថា កិច្ចស៊ើបសួរបឋមគឺជាការរំលោភបំពានលើបទប្បញ្ញត្តិស្ដីពីយុត្តាធិការលើរូបបុគ្គលក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក. និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. មានកំហុស[116]។ នៅគ្រប់កាលៈទេសៈ វិការៈផ្នែកនីតិវិធីត្រូវបានផ្ដល់សំណងតាមរយៈការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ទៅសហចៅក្រមស៊ើបអង្កេត និងដោយសារការខកខានរបស់ភាគី ឬសហចៅក្រមស៊ើបអង្កេតក្នុងការបង្ហាញពីមោឃភាពក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរនោះ[117]។

43. ជាការឆ្លើយតប សហមេធាវីការពារក្ដី យឹម ទិត្យ បានលើកឡើងថា (១) ការចេញដីកាដំណោះស្រាយពីរ គឺជាការខុសច្បាប់ និងថា ដីកាទាំងពីរពុំមានសុពលភាព (២) ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្របច្បាប់ក្នុងរឿងក្ដី ០០៤ និងថា សហព្រះរាជអាជ្ញាអន្តរជាតិពុំបានបង្ហាញហេតុផលដែលជឿបាន ដោយពុំត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី ០០៤/២ (៣) សហចៅក្រម

---

112 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥២។

113 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥២-៥៤។

114 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៨។

115 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៩-៦២។

116 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦៣-៦៦។

117 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦៧-៧១។

ស៊ើបអង្កេតបច្ចុប្បន្នមានយុត្តាធិការពិសេស និង (៤) អង្គជំនុំជម្រះតុលាការកំពូលគប្បីត្រូវបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិដោយពុំចាំបាច់ពិនិត្យលើអង្គសេចក្តី[118]។

## V. ការពិភាក្សា

44. ដូចក្នុងរឿងក្តី ០០៣ ជាការសោកស្តាយដែលខ្ញុំយល់ឃើញខុសពីសហសេវិកចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលលើវិធីសាស្ត្រផ្ទាល់ខ្លួនចំពោះសំអាងហេតុផ្នែកច្បាប់សម្រាប់ការបញ្ចប់ក្នុងរឿងក្តីនេះ។ បើទោះបីជាយើងយល់ស្របថា ជាការសមស្របដែលយើងគប្បីអនុវត្តយុត្តាធិការដែលជាឆន្ទានុសិទ្ធិក្នុងការផ្តល់ការបំភ្លឺ និងដំណោះស្រាយក៏ដោយ ក៏យើងនៅតែខ្វែងយោបល់គ្នាលើមូលហេតុដែលរឿងក្តីនេះគប្បីត្រូវបញ្ចប់។ មតិជំទាស់របស់ខ្ញុំលើកហួសពីការពិតដែលថា សេចក្តីសម្រេចអង្គបុរេជំនុំជម្រះខកខានក្នុងការបង្កើតដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព និងបានពិនិត្យលើស្នាមប្រេះបែកក្នុងកិច្ចដំណើរការនីតិវិធី។ មតិរបស់ខ្ញុំពិចារណាឃើញគឺថា ជាការពុំសក្តិសមដែលត្រូវប្រឹងប្រែងដោះស្រាយដើម្បីឱ្យបង្គាប់ការបញ្ចប់រឿងក្តីនេះ ដោយសារកង្វះដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពហើយពុំអើពើលើអំណះអំណាងត្រឹមត្រូវរបស់ម្ចាស់សំណើ និងពុំអើពើលើវិការៈច្បាស់ក្រឡែតនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងប្រវត្តិនីតិវិធីនៃរឿងក្តីនេះ។ ការអនុញ្ញាតឱ្យដំណើរការនីតិវិធីមុនការជំនុំជម្រះ និងលើករឿងចាស់ដដែលៗដែលលែងគួរឱ្យចាប់អារម្មណ៍មកសំអាងថា កិច្ចស៊ើបសួរបឋមដោយសហព្រះរាជអាជ្ញាអន្តរជាតិ គឺជាការខុសច្បាប់ និងថា សុខ អាន បានបញ្ជាក់នៅមុខសភាតំណាងជាតិថា មានតែបុគ្គលប្រាំនាក់ប៉ុណ្ណោះដែលត្រូវធ្វើការចោទប្រកាន់នោះ គឺជាការពុំអើពើទៅលើការពិត។ ចំណុចនេះត្រូវបានដោះស្រាយនៅក្នុងមតិជំទាស់នៅក្នុងសេចក្តីសម្រេចរឿងក្តី ០០៣ ប្រហាក់ប្រហែលគ្នាដែលពាក់ព័ន្ធនឹង មាស មុត[119]។ បញ្ហានេះត្រូវបានលើកឡើងកាន់តែច្បាស់ដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងរឿងក្តីនេះ នៅពេលដែលគាត់រៀបរាប់អំពីអង្គហេតុជាច្រើនដែលសំខាន់ៗទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី [120]។ ក្នុងសេចក្តីសម្រេចរឿងក្តី ០០៣ សេចក្តីសន្និដ្ឋានរបស់ខ្ញុំផ្អែកទៅលើឯកសារដែលបានដាក់ដោយសហព្រះរាជអាជ្ញាជាតិនៅក្នុងការខ្វែងយោបល់គ្នាលើកដំបូងដែលបានបញ្ជូនមកចំពោះមុខអង្គបុរេជំនុំជម្រះ និងត្រូវបានធ្វើឡើងនៅក្នុងសារណាសហព្រះរាជអាជ្ញាអន្តរជាតិ។ ជាអកុសល

---

118 សារណាតបរបស់ យឹម ទិត្យ កថាខណ្ឌ ៣៤-៤០ ទំព័រ ១៥។

119 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី ០០៣ (3/1/1/1) មតិជំទាស់របស់ចៅក្រម Maureen Clark។

120 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥៨-៦៦។

ដែលឯកសារនោះពុំត្រូវបានពិនិត្យដោយល្អិតល្អន់សិនជាជាងសំអាងទៅលើទាំងងងឹតងងល់ថា ជាអត្ថបទគោលនយោបាយដែលជាក់ស្តែងពុំត្រឹមត្រូវឡើយ។

45. អ្នកនយោបាយមានបទពិសោធន៍ចាស់ទុំគួរឱ្យគោរព និងមានចិត្តសប្បុរធម៌ពីររូបគឺលោក John Stuart MILL និង Edmund BURKE អ្នកទាំងពីរត្រូវបានកោតសរសើរដោយសារបាននិពន្ធសុភាពសិត ដ៏វៃឆ្លាតមួយឃ្លាថា៖ *មានតែការកុំតបតតែម្យ៉ាងគត់របស់មនុស្សល្អ ទើបអាចយកឈ្នះលើអំពើអាក្រក់បាន*។ ខ្ញុំមានទស្សនៈថា សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាមនុស្សល្អ ដែលហ៊ាននិយាយ និងធ្វើអ្វីជាច្រើន និងសក្តិសមទទួលបានការគោរពពេញលេញ។ គាត់ដោះស្រាយចំពោះអំណះអំណាងដែលគួរឱ្យធុញទ្រាន់ថា កិច្ចស៊ើបសួរដំបូងនោះគឺជាការខុសច្បាប់ និងបានលើកបង្ហាញទឡ្ហីករណ៍ជំទាស់ផ្អែកលើអង្គហេតុ។ គាត់បានធ្វើអ្វីៗទាំងអស់ក្នុងសិទ្ធិអំណាចរបស់គាត់ក្នុងការបំពេញតាមអាណត្តិរបស់ខ្លួន និងរបស់ អ.វ.ត.ក. ក្នុងការនាំយកមកកាត់ទោស អ្នកដែលត្រូវបានសង្ស័យមានការទទួលខុសត្រូវតាមរយៈការសមគំនិតក្នុងឧក្រិដ្ឋកម្មគួរឱ្យរន្ធត់ ដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហមក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចអ្វីដែលខ្ញុំបានរៀបរាប់ក្នុងរឿងក្តី ០០៣ អង្គហេតុដែលត្រូវបានផ្អែកទៅលើដោយបុគ្គលិកការិយាល័យជាតិនៅ អ.វ.ត.ក. ត្រូវបានជំទាស់តវ៉ា ប៉ុន្តែពុំដែលត្រូវបានដោះស្រាយ។ ទោះជាយ៉ាងណាក្តីសម្រាប់អត្ថប្រយោជន៍នៃអំណះអំណាង ឧបមាថា សហព្រះរាជអាជ្ញាជាតិបង្ហាញត្រឹមត្រូវក្នុងការអះអាងរបស់ខ្លួនដដែលៗក្នុងពេលបច្ចុប្បន្នដែលថា (១) កិច្ចស៊ើបអង្កេតបឋមដែលញ៉ាំងឱ្យសហព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីនោះ ពុំមានការជូនដំណឹង ឬការយល់ព្រម និង(២) មានការបញ្ជាក់ច្បាស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាថា ពុំមានការជំនុំជម្រះបន្ថែមទៀតក្រៅពី ឌុច អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន នោះទេ ដូចនេះសំណួរបន្ទាប់គឺថា៖

1. តើមូលហេតុអ្វីបានសហព្រះរាជអាជ្ញាជាតិ ពុំដាក់សំណើណាមួយស្របតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងទៅអង្គបុរេជំនុំជម្រះតាំងពីលើកដំបូងក្នុងឆ្នាំ ២០០៩ រហូតមក ដើម្បីមោឃភាពកិច្ចស៊ើបសួរលើជនសង្ស័យដែលក្លាយជាកម្មវត្ថុនៃរឿងក្តីក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី និងទីបួន ?
2. តើមូលហេតុអ្វីបានជាមានការចាំបាច់ត្រូវរក្សាទុកបុគ្គលិកអ្នកស៊ើបអង្កេតច្រើនក្នុងការិយាល័យសហព្រះរាជអាជ្ញា បើកាលណាពុំមានការជំនុំជម្រះបន្ថែមត្រូវបានរំពឹងទុក និងមូលហេតុអ្វីបានជាពួកគេត្រូវនៅទីនោះ?

3. តើមូលហេតុអ្វីបានជាមានការចាំបាច់ត្រូវមានការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានស៊ើបអង្កេតឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងចារីក្នុងសំណុំរឿង ០០៣ និង ០០៤ នៅពេលដែលមានការបញ្ជាក់ពី សុខ អាន ថា ពុំមានភាពចាំបាច់ត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀតនោះ?
4. តើមូលហេតុអ្វីបានជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលលាឈប់នោះត្រូវបានបន្តវេន ដោយមានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រសិនបើពុំមានការស៊ើបអង្កេតបន្ថែមនោះ?
5. តើមូលហេតុអ្វីបានមានសាក្សីជាច្រើន និងជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ នៅពេលគោលនយោបាយបញ្ជាក់ថា ពុំមានការជំនុំជម្រះបន្ថែមនោះ?
6. តើមូលហេតុអ្វីបានជាជនរងគ្រោះជាច្រើន និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឱ្យចូលរួម និងផ្តល់ក្តីរំពឹងទុកនូវថ្ងៃចូលក្នុងតុលាការ ប្រសិនបើពុំមានលទ្ធភាពនៃការជំនុំជម្រះបន្ថែមនោះ?

46. តើរយៈពេល ១៣ ឆ្នាំចុងក្រោយនេះ ត្រឹមតែជាការអនុវត្តន៍វិទ្យាសាស្ត្រខាងទស្សនសម្ព័ន្ធដ៏មានតម្លៃថ្លៃមួយប៉ុណ្ណោះ ឬ? តើច្បាប់ស្តីពីការពន្យារពេលលើសពីធម្មតា និងពុំអាចអនុគ្រោះឱ្យបាន ក្នុងការប្រើប្រាស់សិទ្ធិ និងច្បាប់ស្តីពីការបោះបង់សិទ្ធិតាមរយៈអំពើនៅស្ងៀមនោះ អនុវត្តទៅលើសហព្រះរាជអាជ្ញាជាតិដែរ ឬទេ ? តើច្បាប់ព្រហ្មទណ្ឌអន្តរជាតិបិទភ្នែក និងអនុញ្ញាតឱ្យភាគីដែលខកខានក្នុងការប្រើប្រាស់កាតព្វកិច្ចរបស់ខ្លួនដាក់សំណើសុំមោឃភាពតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ឬផ្អែកតាមនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នាដែលមានចែងក្នុងវិធានផ្ទៃក្នុង ដើម្បីសំអាងទៅលើសម្រាប់បញ្ហាទាំងនោះ ធ្វើជាមូលហេតុសម្រាប់ការបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ? តើនេះ គឺជាបញ្ហាដែលថាដោយសារដីកាដំណោះស្រាយផ្ទុយគ្នា ទើបគ្មានអ្វីក្រៅតែពីផលវិបាកជៀសពុំរួចនៃបញ្ហាយុត្តាធិការដែលគ្មានដំណោះស្រាយ ឬការពិត គឺជាការបង្ហាញជំហរខាងជាតិថា ពុំអាចមានការជំនុំជម្រះបន្ថែមក្រៅពីសំណុំរឿង ០០១ និង ០០២ នោះទេ ?

47. បញ្ហានយោបាយបានធ្វើឱ្យអំណះអំណាងទៅជារឿងឥតប្រយោជន៍ដូចបានលើកឡើងក្នុងមតិជំទាស់របស់ខ្ញុំក្នុងរឿងក្តី ០០៣។ តុលាការត្រូវជៀសវាងការចេញដីកាសម្រេចដែលពុំត្រូវបានគោរព ឬពុំអាចអនុវត្តបាន។ តើត្រូវធ្វើយ៉ាងណាទើបជាការសមស្របត្រឹមត្រូវក្នុងកាលៈទេសៈនេះ និងតើត្រូវធ្វើយ៉ាងណាឱ្យស្របតាមបទដ្ឋានអន្តរជាតិក្នុងការបដិសេធសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅពេលដឹង

ជាក់ច្បាស់ថា គោលនយោបាយស្តីពីការដែលពុំមានការជំនុំជម្រះបន្ថែម នឹងត្រូវបានយកមកប្រើប្រាស់ដើម្បីរារាំងដល់កិច្ចប្រតិបត្តិការយន្តការស្វ័យប្រវត្តិនោះ? តើត្រូវធ្វើយ៉ាងណាទើបជាការសមស្របត្រឹមត្រូវក្នុងការស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុបន្ថែមក្នុងការពុះពារបន្ថែមដើម្បីបង្គាប់ឱ្យមានការពិនិត្យឡើងវិញសមស្របលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមានវិការៈក្នុងកាលៈទេសៈដែលមានការលើកឡើងថា កិច្ចស៊ើបសួរបឋមនោះ គឺជាការខុសច្បាប់ ដោយសារ*សហព្រះរាជអាជ្ញាអន្តរជាតិបានបើកកិច្ចស៊ើបសួរបឋមសម្ងាត់ជាឯកតាភាគីដោយពុំបានជូនដំណឹង និងទំនាក់ទំនងជាមួយសហព្រះរាជអាជ្ញាជាតិ ...ដែលនេះជាការប្រឆាំងនឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលតម្រូវឱ្យមានសហព្រះរាជអាជ្ញាទាំងពីរធ្វើការជាមួយគ្នា*។

48. នេះជាអំណះអំណាងដែលចោទសួរជាច្រើនសំណួរ ដូចជា តើមូលហេតុអ្វីបាន កិច្ចស៊ើបសួរបន្ថែមលើជនសង្ស័យលំដាប់ទីពីរក្នុងការិយាល័យសហព្រះរាជអាជ្ញាដែលគោលបំណងសំខាន់បំផុត គឺដើម្បីយកមកកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងអំឡុងពេលនៃចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ត្រូវបានចាត់ទុកថាខុសច្បាប់ ? តើមូលហេតុអ្វីបានជាសហព្រះរាជអាជ្ញាជាតិពុំធ្វើចំណាត់ការស៊ើបសួរបន្ថែម និងសហការជាមួយសហសេវិកព្រះរាជអាជ្ញាក្នុងការបំពេញអាណត្តិការិយាល័យរបស់ខ្លួន ? មូលហេតុដែលបានផ្តល់ដោយមានការស្នាក់ស្ទើរពីសហព្រះរាជអាជ្ញាជាតិក្នុងការឯកភាពតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ពុំមែនថា សហព្រះរាជអាជ្ញាគាត់ពុំបានដឹង និងពុំបានជាប់ពាក់ព័ន្ធទៅនឹងនីតិវិធីស៊ើបអង្កេតនោះទេ ប៉ុន្តែដោយសារគាត់ពុំយល់ស្របជាមួយនឹងភាពចាំបាច់នៃការស៊ើបសួរបន្ថែម ពីព្រោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនោះត្រូវបានគ្របដណ្តប់រួចហើយដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០១ និង ០០២។ អំណះអំណាងនៃ"កិច្ចស៊ើបសួរសម្ងាត់ឯកតោភាគី" ទើបតែបានលើកឡើងដំបូងក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះប៉ុណ្ណោះ។ ពុំមានប្រវត្តិនៃអំណះអំណាងបានបង្ហាញភាពសមស្របឡើយ លើកលែងតែមានការទទួលស្គាល់ថា នេះគឺជាគោលនយោបាយទូទៅ និងពុំអាចសម្របសម្រួលបានរបស់រដ្ឋាភិបាលក្នុងការរារាំងរាល់ការជំនុំជម្រះក្រៅតែពីសំណុំរឿង ០០១ និង ០០២។

49. ការអនុវត្តន៍គោលនយោបាយនេះ បានចម្លងមេរោគដល់ការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ គួររំឭកថា ចៅក្រមអង្គបុរេជំនុំជម្រះបានយល់ឃើញថា សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតគឺជាការ

ខុសច្បាប់ ប៉ុន្តែពុំអើពើទៅនឹងការបដិសេធផ្នែកយុត្តាធិការ ចៅក្រមទាំងប្រាំរូបនេះបានបន្តពិចារណាលើសុពលភាពនៃដីកាសម្រេចដែលបានធ្វើឡើងតាមរយៈវិធីខុសច្បាប់នោះ។ ចៅក្រមជាតិបីរូបបានតម្កល់ធម្មានុរូបនៃដីកាសម្រេចលើកលែងចោទប្រកាន់ ដោយផ្អែកលើមូលដ្ឋានថា យឹម ទិត្យ ដែលប្រឈមកិច្ចស៊ើបសួរពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទឧក្រិដ្ឋក្នុងស្រុក ពុំបានបំពេញតាមលក្ខខណ្ឌនៃយុត្តាធិការឡើយ។ ចៅក្រមជាតិបានសំអាងផងដែរលើអំណះអំណាងនៃកិច្ចស៊ើបសួរបឋមដែលខុសច្បាប់។ ចំណែកឯចៅក្រមអន្តរជាតិពីររូបនៃអង្គបុរេជំនុំជម្រះបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋានថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះ និងតួនាទីរបស់ជនសង្ស័យ គ្របដណ្តប់លើវិសាលភាពនៃកម្មាភិបាលខ្មែរក្រហមដែលជាបុគ្គលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចៅក្រមអន្តរជាតិបានពិនិត្យលើអង្គហេតុដែលបានបង្ហាញយ៉ាងលម្អិត និងបានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះគប្បីត្រូវតម្កល់។

50. ផ្អែកតាមគោលការណ៍ស្តីពីយុត្តិធម៌ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះពុំមានសុពលភាព និងគប្បីត្រូវបានបដិសេធចោលដោយសារភាពពុំសមស្រប ការខកខានរបស់ខ្លួនក្នុងការអនុញ្ញាតឱ្យយន្តការស្វ័យប្រវត្តិអាចប្រតិបត្តិការបាន និងខកខានក្នុងការផ្តល់ការបំភ្លឺផ្នែកច្បាប់ និងការបញ្ចប់ចុងក្រោយ។ សំណើបច្ចុប្បន្ន និងពីមុនរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹង មាស មុត បានលើកបញ្ហាគួរឱ្យរំខាននៅចំពោះមុខអង្គជំនុំជម្រះចុងក្រោយនៃ អ.វ.ត.ក.នេះ និងក្នុងពេលដដែលនេះបង្ហាញថា ពុំមានអត្ថប្រយោជន៍ណាសោះឡើយក្នុងការបង្គាប់ឱ្យធ្វើចំណាត់ការសារឡើងវិញតាមរយៈការស្តាប់បណ្តឹងឧទ្ធរណ៍នោះសាជាថ្មី។

51. ផ្អែកតាមហេតុផលនោះ ពុំមានលទ្ធភាពដែលបើកចំហសម្រាប់អង្គជំនុំជម្រះនេះឡើយ ក្រៅតែពីទទួលស្គាល់ថា ចំណាត់ការបន្ថែមផ្តល់សំណងលើការខ្វែងយោបល់គ្នាដែលពុំអាចសម្របសម្រួលបានរវាងសមាសភាពជាតិ និងអន្តរជាតិនៃដំណើរការនីតិវិធីមុនការជំនុំជម្រះនោះ គឺរឿងឥតប្រយោជន៍។ ការពិតដែលពុំអាចជៀសផុត តម្រូវឱ្យប្រើប្រាស់វិធីសាស្ត្រចាំបាច់ចុងក្រោយ គឺការបញ្ចប់រាល់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង យឹម ទិត្យ។

52. អ្វីដែលខ្ញុំសរសេរនេះ គឺកើតចេញពីទស្សនទានជាចៅក្រមអន្តរជាតិដែលត្រូវបានដាក់កិច្ចការឱ្យប្រតិបត្តិតាមបទដ្ឋានគតិយុត្តិអន្តរជាតិកម្រិតខ្ពស់។ មតិជំទាស់នេះគឺជាគោលគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំអំពីការពិតដែលមានអត្ថិភាពប៉ុណ្ណោះ។ នៅមានការខ្វែងយោបល់គ្នាជាច្រើន និងឯកសារពាក់ព័ន្ធប្រហាក់ប្រហែលគ្នាដែលនៅរក្សាការសម្ងាត់។ មតិជំទាស់នេះបានផ្អែកលើមូលដ្ឋាននៃឯកសារដែលបានបង្ហាញក្នុងរឿងក្តី ០០៤ និងរឿងក្តីរបស់ អោ អាន និង មាស មុត (រឿងក្តី ០០៤/២ និង ០០៣ នីមួយៗ)។ ខ្ញុំសូមបញ្ជាក់សាឡើងវិញថា ចៅក្រមជាតិបានប្រព្រឹត្តស្របតាមមនសិការរបស់ខ្លួន និងវប្បធម៌ និងទស្សនទានដែលខុសប្លែកគ្នាពីខ្ញុំទាក់ទងទៅនឹងការបំពេញមុខនាទី និងកាតព្វកិច្ច។ មានការទទួលស្គាល់ថា គោលជំហររបស់ខ្ញុំពុំសូវរឹងមាំដោយសារការពិតដែលថា ខ្ញុំពុំត្រូវបានគាំទ្រដោយសហសេវិកចៅក្រមជាតិ ឬអន្តរជាតិរបស់ខ្ញុំ។ បើទោះបីជាយើងមានការខ្វែងយោបល់គ្នាយ៉ាងណាក៏ដោយ ក៏សមាសភាពក្រុមប្រឹក្សានៃអង្គជំនុំជម្រះតុលាការកំពូលទាំងមូលបានផ្តល់ការគោរពពេញលេញ និងភាពគួរសមចំពោះមតិជំទាស់របស់ខ្ញុំ។

ទីក្រុង Cork ប្រទេសអៀរឡង់ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល**



ចៅក្រម **Maureen HARDING CLARK**